បោះពុម្ពផ្សព្វផ្សាយដោយ

CIUS
CAMBODIAN INSTITUTE FOR URBAN STUDIES

គាំទ្រជាផ្លូវការដោយ




## ឧបករណ៍បរិវត្តកម្មនៃគម្រោង B4P

# សេចក្តីណែនាំអំពីអភិបាលកិច្ច និង ការចូលរួម

០២.៦


ឧបត្ថម្ភដោយ

Federal Ministry of Research, Technology and Space

FONA
Research for Sustainability

SURE
Sustainable Development of Urban Regions




**រូបភាពទី១៖** ការបោះពុម្ពគោលការណ៍ណែនាំនេះ ជាផ្នែកមួយនៃ B4P Transformation Toolbox ដែលជាវេទិកាសិក្សាដ៏ទូលំទូលាយមួយ ដែលបង្កើតឡើងដោយគម្រោង Build4People សហការជាមួយសាលារាជធានីភ្នំពេញ ដើម្បីជំរុញការអភិវឌ្ឍន៍សហគមន៍ប្រកបដោយនិរន្តរភាពក្នុងទីក្រុងនៃប្រទេសកម្ពុជា។

# ០២.៦
# G&P

# ការអភិបាលកិច្ច និងការចូលរួម

## មាតិកា


សេចក្ដីណែនាំ 04
» ផលកម្រៃ សេដ្ឋកិច្ច សង្គម និងបរិស្ថាន
» មូលដ្ឋានវិទ្យាសាស្ត្រ និងគំនិតចម្បងៗ
I បរិយាប័ន្ន និងការគិតគូរអំពីយែនឌ័រ វិធីសាស្ត្រនៃការរៀបចំទីក្រុង 10
II ការរៀបរស់នៅប្រកបដោយចីរភាព 12
» ការដាក់តាំងពិព័ណអនឡាញរបស់គម្រោង B4P " អ្នកផ្ដួចផ្ដើមបៃតងនៃប្រទេសកម្ពុជា "
III ការផ្ដួចផ្ដើម 14
» ការសិក្សាអំពីការរស់នៅក្នុងទីក្រុង៖ ការសិក្សាអំពីបរិវត្តកម្មនៃទីក្រុងអេកូឡូស៊ីរបស់ B4P
» អន្តរាគមន៍អភិបាលកិច្ចបរិវត្តកម្ម៖ សកម្មភាពនៃការរៀបចំដោយគម្រោង B4P
» កំណត់ចក្ខុវិស័យ និងទិសដៅរួម៖ តាមរយៈកម្មវិធីលើកកម្ពស់ B4P-SMMR
IV ការរៀបចំផែនការ 20
» ឧបករណ៍រៀបចំផែនការបែបឌីជីថល៖ UCode
V ការវាយតម្លៃ និងការស្រាវជ្រាវ 22
» កម្មវិធីសម្រាប់ផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋ
» សហការរៀបចំបរិវត្តកម្មទីក្រុង
VI សកម្មភាពអនាគត 28
VII ឯកសារយោង 29



Version: ១.០
*កែសម្រួលចុងក្រោយនៅ ១១.មិថុនា.២០២៥*

ក្រាហ្វិកនៃគម្រូបឯកសារ៖
Uddam Pen, Prosob Media, Phnom Penh.




# ០២.៦ G&P

# ការអភិបាលកិច្ច និងការចូលរួម

## សេចក្តីណែនាំ

ការរៀបចំទីក្រុង ការការពារអាកាសធាតុ និងរបៀបដែលយើងប្រើប្រាស់ធម្មជាតិ និងធនធាន ត្រូវបានទទួលឥទ្ធិពល ដោយការសម្រេចចិត្ត និងតាមចរិកលក្ខណៈបុគ្គល។ ក្នុងពេលជាមួយគ្នានេះដែរ ការសម្រេចចិត្តបែបនោះក៏បណ្តាលអោយមានផលប៉ះពាល់ ទៅដល់បុគ្គលម្នាក់ៗផងដែរ។ ដូច្នេះការព្យាយាមយកមតិភាគច្រើនក្នុងការអភិវឌ្ឍន៍ និងអនុវត្តន៍នៃគោលបំណងសមស្របនានាគឺជាកត្តាគន្លឹះ។ ការផ្លាស់ប្តូរនេះបានកំណត់បរិវត្តកម្មពីអភិបាលកិច្ចជាប្រចាំទៅរកវិធីសាស្ត្រការចរចារ និងការចូលរួមពីប្រជាពលរដ្ឋ។

កិច្ចការនេះត្រូវបានគេជម្រុញក្នុងកម្រិតគោលនយោបាយរយៈពេល ២៥ឆ្នាំមកហើយ។ នាដើមឆ្នាំ ១៩៩២ សេចក្តីប្រកាសរួមស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍នៅទីក្រុងរីយ៉ូ បានអំពាវនាវអោយមានការចូលរួមដោះស្រាយទៅលើបញ្ហាបរិស្ថាន។ ចាប់តាំងពីពេលនោះមក និន្នាការនេះបានមានសន្ទុះកើនឡើង តាមយន្តការនៃការចូលរួមក្នុងការកសាងផែនការនានាក្នុងបរិបទបរិស្ថាន។ វិសាលភាពនៃការអនុវត្តនេះ ត្រូវបានពង្រីកក្នុងការរៀបចំទីក្រុង សមាហរណកម្មការរចនាទីប្រជុំជន ការកសាងផែនការដឹកជញ្ជូន និងការរៀបចំដង់ស៊ីតេទីក្រុង។

ការប្រឈមនោះ គឺការអនុវត្តការផ្តួចផ្តើមរួមគ្នា និងការចូលរួមក្នុងក្របខ័ណ្ឌ ដែលតម្រូវតាមផ្នត់នយោបាយ ដែលសំដៅទៅដល់ការលើកកម្ពស់គុណភាពជីវិតក្នុងទីក្រុង និងធានាការប្រើប្រាស់ធនធានប្រកបដោយចីរភាព។ វិធីសាស្ត្រជាច្រើនបានរីកដុះដាល ដោយមានការចូលរួមដោយសកម្មនោះ។ ទោះជាយ៉ាងណាក្តី ទស្សនៈនៃការចូលរួមមានភាពខុសគ្នា៖ តើគួរតែបើកលំហនៃឥទ្ធិពលនៅក្នុងកម្រិតណា? នរណាគួរចូលរួម? ដើម្បីអ្វី?

សំណួរទាំងនេះ មានការលំបាកក្នុងការរៀបចំអោយមានការចូលរួម និងវាយតម្លៃភាពជោគជ័យ។ ការកំណត់គោលបំណងច្បាស់លាស់ និងលក្ខខណ្ឌនៃការចូលរួម និងធានាការពិភាក្សាដោយអត្ថន័យ និងអភិបាលកិច្ចទីក្រុងប្រកបដោយប្រសិទ្ធភាព។




**រូបភាពទី២៖** ទម្រង់ច្រើននៃការចូលរួម
ប្រភពនៃក្រាហ្វ៖ គម្រោង B4P
ប្រភពនៃរូបភាព៖ Michael Waibel (ឆ្នាំ២០២៥)

## អត្ថប្រយោជន៍ សេដ្ឋកិច្ច សង្គម និងបរិស្ថាន

ការប្រើប្រាស់វិធីសាស្ត្រនៃការចូលរួមអោយបានកាន់តែច្រើន បានជួយបង្កើនផលសមាហរណកម្ម នូវចំណាប់អារម្មណ៍ពីអ្នកចូលរួមពីប្រភពផ្សេងៗគ្នា និងក្រុមប្រជាពលរដ្ឋក្នុងការកសាងផែនការ តម្រូវតាមការចង់បានរបស់សហគមន៍ និងអ្នកប្រើប្រាស់។ ការព្យាយាមអោយមានអ្នកចូលរួមបែបជាប្រព័ន្ធ មិនគ្រាន់តែជួយការពារមិនអោយ មានកំហុសក្នុងការកសាងផែនការប៉ុណ្ណោះទេ ប៉ុន្តែក៏បានពង្រឹងនូវអត្តសញ្ញាណសហគមន៍ជាមួយទីក្រុង និងទីប្រជុំជនរបស់ពួកគេ។ ការចូលរួមរបស់ប្រជាពលរដ្ឋជាប្រចាំដូចជាមកជំនាញនៅពីដើមគ្រានៃការកសាងផែនការនឹងជួយដល់អ្នកអភិវឌ្ឍន៍ និងអាជ្ញាធរបង្កើតលំហការរស់នៅក្នុងទីក្រុងមួយ ដែលមានចីរភាពផ្នែកអេកូឡូស៊ី សង្គម និងសេដ្ឋកិច្ច។

### អត្ថប្រយោជន៍សេដ្ឋកិច្ច សម្រាប់អ្នកអភិវឌ្ឍន៍វិស័យឯកជន

ការបង្កើនរួមគ្នា និងការចូលរួមអាចផ្តល់ផលចំណេញជាច្រើនដល់អ្នកអភិវឌ្ឍន៍៖

- **បង្កើនភាពទាក់ទាញលើទីតាំងគម្រោង៖** ដំណើរការនៃការចូលរួម ជួយធ្វើឲ្យគម្រោងមានសមាហរណកម្មប្រសើរថែមទៀត ជាមួយបរិស្ថានទីក្រុង ដែលផ្តល់ភាពទាក់ទាញដល់អ្នកទិញ និងអ្នកជួលអគារ។
- **ការអភិវឌ្ឍន៍ដែលមានចីរភាព និងបំពេញតាមតម្រូវការទីផ្សារ៖** ការចូលរួមពីដៃគូពាក់ព័ន្ធ ធ្វើឲ្យងាយយល់អំពីតម្រូវការចំពោះមុខនៃអ្នកប្រើប្រាស់នៅអនាគត ហើយគេអាចបំពេញតម្រូវការបានទាន់ពេលវេលា។ វាក៏ជួយអោយមានកំណើននៃតម្រូវការជាក់ស្តែង។
- **បង្កើនតម្លៃអគាររយៈពេលវែង៖** គម្រោងដែលផ្សារភ្ជាប់សង្គម និងបរិស្ថានតែងតែមានតម្លៃបានយូរ ព្រោះការរៀបចំគម្រោងបានបញ្ជ្រាបជាមួយស្ថានភាពទីក្រុង ហើយរក្សាបានតម្រូវការ ដែលមានលំនឹង។

### អត្ថប្រយោជន៍សេដ្ឋកិច្ចសម្រាប់ អាជ្ញាធរមូលដ្ឋាន

អាជ្ញាធរសាធារណៈ អាចបង្កើនចំណូលដល់សេដ្ឋកិច្ចបានច្រើនអំពីដំណើរការនការចូលរួម និងសហផលិត។

- **ការលើកទឹកចិត្តដល់ធុរៈកិច្ច៖** សហផលិតជម្រុញនវានុវត្ត ដោយការធ្វើសមាហរណកម្មធុរកិច្ចមូលដ្ឋាន ការចាប់ផ្តើមសហគ្រាស និងសហគ្រិនសង្គ មនៅក្នុងគម្រោងរបស់រដ្ឋ។
- **ហេដ្ឋារចនាសម្ព័ន្ធ ចីរភាព និងមានភាពធន់៖** គម្រោងដែលមានធាតុចូលពីសហគមន៍ច្រើនមានចីរភាព និងងាយអនុវត្តហើយកាត់បន្ថយការចំណាយ លើការកែសម្រួលនាពេលអនាគត។
- **ការថែទាំមានតម្លៃទាប៖** នៅពេលដែលប្រជាពលរដ្ឋបានចូលរួមរៀបចំ និងអនុវត្តគម្រោង ពួកគេច្រើនតែយកចិត្តទុកដាក់ថែរក្សាទ្រព្យសម្បត្តិរដ្ឋ ដែលជាកត្តាកាត់បន្ថយការចំណាយលើការថែទាំ។

### អត្ថប្រយោជន៍ បរិស្ថាន

ដោយការចូលរួមពីមហាជន អ្នកអភិវឌ្ឍន៍អាចបង្កើតគម្រោង ដែលទទួលខុសត្រូវផ្នែកបរិស្ថាន ដែលធ្វើឲ្យគម្រោងនោះកាន់តែមានភាពធន់៖

- **ការដំណោះស្រាយថាមពលប្រកបដោយប្រសិទ្ធភាព៖** កាផ្សារភ្ជាប់អ្នកពាក់ព័ន្ធអាចបង្កើតបរិយាកាសគំនិតនវានុវត្ត
- **សមាហរណកម្មបានល្អ ជាមួយប្រព័ន្ធអេកូឡូស៊ីមូលដ្ឋាន៖** ការចូលរួមពីសហគមន៍អាចជួយឱ្យអ្នកអភិវឌ្ឍន៍រចនាគម្រោងឱ្យស្របតាមទេសភាពធម្មជាតិ ដើម្បីរក្សាទុកតំបន់បៃតង និងជីវចម្រុះ។

### អត្ថប្រយោជន៍ សង្គម

អាជ្ញាធរសាធារណៈ និងប្រជាពលរដ្ឋអាចទទួលបានអត្ថប្រយោជន៍សង្គមជាច្រើនពីដំណើរការចូលរួម និងការសហការ៖

- **ការកែលម្អគុណភាពជីវិត និងសុខុមាលភាពក្នុងទីក្រុង៖** គម្រោងផ្អែកលើ អ្នកប្រើប្រាស់ និងដឹកនាំដោយសហគមន៍អាចបង្កើនភាពរស់នៅក្នុងទីក្រុង ធ្វើឱ្យប្រជាជនមានសុខភាពល្អជាងមុន។
- **ការពង្រឹងទំនុកចិត្តសង្គម៖** នៅពេលដែលប្រជាពលរដ្ឋមានអារម្មណ៍ថា មតិរបស់គាត់ត្រូវបានទទួលយក និងបញ្ចូលក្នុងផែនការ ពួកគេនឹងបង្កើនទំនុកចិត្តកាន់តែច្រើន លើស្ថាប័នសាធារណៈ។
- **ការលើកទឹកចិត្តឱ្យមានកាតព្វកិច្ចស៊ីវិល៖** ការចូលរួមបង្កើតស្មារតី និងភាពជាម្ចាស់កម្មសិទ្ធ ធ្វើឱ្យមនុស្សមានការចាប់អារម្មណ៍កាន់តែច្រើន នៅក្នុងការចូលរួមថែរក្សាតំបន់សាធារណៈ និងសេវាកម្ម។
- **ការកែលម្អភាពងាយស្រួលក្នុងការប្រើប្រាស់៖** ចូលរួមពីសហគមន៍ជួយរចនាតំបន់ និងសេវាកម្មឱ្យមានភាពរួមបញ្ចូលពិតប្រាកដ ដូចជា គម្រោងហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលងាយស្រួលប្រើប្រាស់ជាសាធារណៈដោយគ្មានឧបសគ្គ។
- **ការបង្កើតសមត្ថភាពធន់ទ្រាំចំពោះវិបត្តិ៖** ប្រជាជន ដែលមានការចូលរួមសង្គមអាចឆ្លើយតបបានល្អជាងមុនចំពោះបញ្ហាប្រឈម ដូចជា ការប្រែប្រួលអាកាសធាតុ ការធ្លាក់ចុះសេដ្ឋកិច្ច ឬវិបត្តិសុខភាព។

ប្រភព៖ ការចងក្រងផ្ទាល់ខ្លួនដោយផ្អែកលើប្រភពផ្សេងៗ។

សេចក្តីណែនាំ ០២.៦

# សារតា និង
# គោលគំនិតសំខាន់ៗ

ការចូលរួមជាទូទៅសំដៅទៅលើ ការពាក់ព័ន្ធរបស់អ្នកទទួលផលក្នុងប្រធានបទនានា បញ្ហាដំណើរការ និងការស្វែងរកដំណោះស្រាយ។ ភាពតានតឹង និងទំហំនៃការចូលរួមអាស្រ័យលើប្រធានបទ និងការរៀបចំកិច្ចពិគ្រោះយោបល់ រួមមានការចែករំលែកព័ត៌មាន ក្នុងការចូលរួមការសម្រេចចិត្ត ឬការរៀបចំដំណើរការសម្រាប់ការចូលរួម (Bell និងMorse, ២០១២)។

ការជ្រើសរើសអ្នកចូលរួមវិធីសាស្រ្ត និងកម្រិតនៃឥទ្ធិពលនៃការបញ្ចេញមតិត្រូវបានកំណត់ដោយមុខងារ និងគោលបំណងនៃសំដៅលើការប្រមូលព័ត៌មាន និងបទពិសោធន៍ពីមជ្ឈដ្ឋានចម្រុះ ដើម្បីគាំទ្រដល់ការសម្រេចចិត្តលើផែនការ នោះគេត្រូវព្យាយាមឲ្យមានការចូលរួមពីអ្នកមានមុខជំនាញចម្រុះច្រើនតាមដែលអាចធ្វើបាន។ ការពិភាក្សារួមមានព្រឹត្តិការជជែកវែកញែក ឧបករណ៍ប្រមូលមតិតាមបែបវិទ្យាសាស្ត្រ កិច្ចពិភាក្សាក្រុម ឬការវាយតម្លៃក្រោយកិច្ចពិគ្រោះយោបល់ ដើម្បីប្រមូលយកធាតុចូលពីការយល់ឃើញ បទពិសោធន៍ និងការចង់បាន។ នេះមិនមានន័យថា វិធីសាស្ត្រមួយអាចប្រមូលធាតុចូលគ្រប់ក្រុមគោលដៅនោះទេ។ ជាចម្បងគេគួរជៀសវាងជ្រើសរើស វិធីសាស្ត្រពិគ្រោះយោបល់ដែលមានលក្ខណ:ជាក្របខ័ណ្ឌផ្លូវការ ឬបែបការសិក្សាស៊ីជម្រៅ ប៉ុន្តែផ្តោតលើការលើកទឹកចិត្តឲ្យមានបរិយាប័ន្ន (Few, Brown, Tompkin, ២០០៧)។

បើគោលបំណង គឺដើម្បីបង្កើនភាពទុកចិត្តលើវិធានការធ្វើផែនការ បង្កើនការជឿជាក់លើការគ្រប់គ្រង និងលើកទឹកចិត្តអោយមានការទទួលខុសត្រូវពីសាធារណៈជនចំពោះទ្រព្យសាធារណៈ សេវាកម្ម និងសមត្ថភាពធន់ទ្រាំនៅមូលដ្ឋាន នោះត្រូវការទម្រង់នៃការចូលរួមមួយដែលសកម្មជាងមុនហើយផ្តល់ឲ្យអ្នកចូលរួមនូវឥទ្ធិពល ឱកាសបង្កើត និងអំណាចក្នុងការធ្វើសេចក្តីសម្រេច (Arnstein, 1975)។ ការចូលរួមមិនមែនជាគោលដៅចុងក្រោយទេ ហើយការអនុវត្ត គឺជាគោលការណ៍មួយមិនអាចធានាឲ្យសម្រេចបានគោលបំណងទាំងនេះដោយស្វ័យប្រវត្តិឡើយ។ ជំនួសឲ្យការសង្កត់ធ្ងន់លើតែបញ្ហា គំនិត និងបំណងប្រាថ្នា គោលបំណងនៃការចូលរួម គឺដើម្បីបង្កើតការសន្ទនា ដែលមានភាពស្មើគ្នា ផ្តល់ឱកាសឲ្យមានការចូលរួមសកម្មក្នុងដំណើរការ និងចាត់ទុកអ្នកចូលរួមជាអ្នកជំនាញប្រចាំថ្ងៃលើបរិយាកាសរស់នៅរបស់ពួកគេ។

ក្នុងបរិបទនេះ Horelli (២០០២) បានផ្តល់ធាតុចូលអំពីដំណើរការធ្វើផែនការចូលរួមដែលមានប្រាំដំណាក់កាល (មើលរូបភាពទី ២)។ នៅក្នុងដំណាក់កាលដំបូង គឺដំណាក់កាលចាប់ផ្តើម គោលបំណងនៃការចូលរួមគួរត្រូវបានបញ្ជាក់ឲ្យច្បាស់ រួមទាំងទស្សនៈពេលវេលា កម្រិតនៃឥទ្ធិពល (ការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ ឬការបង្កើតរួម) និងការសម្រេចចិត្តថា តើត្រូវអញ្ជើញភាគីពាក់ព័ន្ធណាខ្លះចូលរួម។

សំណួរមួយកើតឡើងនៅក្នុងដំណាក់កាលនេះ តើធ្វើដូចម្តេចដើម្បីលើកទឹកចិត្តអ្នកទទួលផលឲ្យចូលរួមក្នុងដំណើរការធ្វើផែនការ ប្រសិនបើពួកគេមិនរំពឹងថានឹងមានអត្ថប្រយោជន៍ឬគុណវិបត្តិណាមួយពីការធ្វើផែនការនោះ។ និតិវិធីនៃការចូលរួមមានសារៈសំខាន់ក្នុងការបង្ហាញឲ្យអ្នកទទួលផលយល់ឃើញថា ដំណើរការចូលរួមក៏ផ្តល់ឱកាសឲ្យគាត់បានជួបអ្នកដទៃ បង្កើតទំនាក់ទំនងសង្គម និងពង្រឹងអារម្មណ៍នៃសមត្ថភាពផ្ទាល់ខ្លួន (van Zomeren, ២០១៥)។ ការធ្វើផែនការអាចទទួលបានជោគជ័យបានប្រសិនបើអ្នកចូលរួមក្នុងដំណើរការ ត្រូវបានយកចិត្តទុកដាក់យ៉ាងពិតប្រាកដ ហើយធាតុចូលរបស់អ្នកចូលរួមត្រូវបានអនុវត្តជាក់ស្តែង។ ក្នុងការអនុវត្ត រាល់ធាតុចូលមិនអាចធ្វើបានទាំងស្រុងទេ។ ដូច្នេះសំខាន់ណាស់ក្នុងការប្រាស្រ័យទាក់ទងអំពីឱកាសនៃឥទ្ធិពលឲ្យមានភាពច្បាស់លាស់ចាប់ពីដើមគ្រា ដើម្បីរក្សាការជឿជាក់របស់អ្នកពាក់ព័ន្ធ សម្រាប់នីតិវិធីធ្វើផែនការនាអនាគតផងដែរ។

ក្នុងដំណាក់កាលធ្វើផែនការ និងរចនាផ្សេងៗនឹងដំណាក់កាលអនុវត្ត គេអាចជ្រើសរើសវិធីសាស្ត្រ និងឧបករណ៍ជាក់លាក់សម្រាប់ឆ្លើយតបទៅនិងគោលបំណងនេះបាន។ ក្រៅពីភាពងាយស្រួលក្នុងការប្រើប្រាស់វិធីសាស្រ្តទាំងនេះមានសារៈសំខាន់ក្នុងការយល់ដឹងពីរបៀបលើកកម្ពស់ក្នុងការចូលរួម ប្រកបដោយភាពយុត្តិធម៌សម្រាប់អ្នកចូលរួម ព្រោះវាជាលក្ខខណ្ឌគន្លឹះសម្រាប់ការទទួលលទ្ធផលពីការធ្វើផែនការ។

Tyler (២០០០) បានកំណត់លក្ខណៈវិនិច្ឆ័យចំនួនបួនសម្រាប់យុត្តិធម៌នៃដំណើរការ៖ (១) ភាពអព្យាក្រឹតរបស់អ្នកធ្វើសេចក្តីសម្រេច (២) ការជឿជាក់របស់អ្នកទទួលផលប៉ះពាល់ពីចេតនារបស់អ្នកធ្វើសេចក្តីសម្រេច (៣) ការប្រព្រឹត្តដោយការគោរព ចំពោះអ្នកពាក់ព័ន្ធទាំងអស់ និង (៤) ឱកាសក្នុងការចូលរួម និងធ្វើឲ្យសំឡេងរបស់ខ្លួនត្រូវបានទទួលដឹងឮ។ ឱកាសក្នុងការបង្ហាញមតិយោបល់របស់ខ្លួន (ការចង់បាន) មានសារៈសំខាន់ជាពិសេសរួមបញ្ចូលទាំងការលើកសរសើរចំពោះមតិ ដែលបានបញ្ចេញផងដែរ (Conrad et al., ២០១១)។

វាអាចជាការប្រឈមនៅពេលអ្នកជំនាញផ្នែកផែនការ និងប្រជាជនទូទៅធ្វើការជាមួយគ្នា។ ក្នុងករណីបែបនេះ ការរៀបចំដំណើរការពិគ្រោះយោបល់ក្លាយទៅជាការចាំបាច់ ដើម្បីគាំទ្រការទំនាក់ទំនងរវាងអ្នកជំនាញ និងអ្នកចូលរួមដើម្បីធានាការគោរពគ្នាទៅវិញទៅមក។ ជាចុងក្រោយគួរមានការវាយតម្លៃលើដំណើរការចូលរួម ដើម្បីកែលម្អនីតិវិធីចូលរួមឲ្យសមស្របនឹងបរិបទនីមួយៗ។




**រូបភាពទី៣៖** និតិវិធីក្នុងការរៀបចំផែនការ ដោយមានការចូលរួមតាមប្រាំជំហាន ។
ប្រភព៖ កែសម្រួលបន្ទាប់ពីសន្និសិទ្ធ Horelli ឆ្នាំ២០០២។

# វិធីសាស្ត្របរិយាប័ន និងចំណាប់អារម្មណ៍យេនឌ័រក្នុងការធ្វើផែនការទីក្រុង






**រូបភាពទី ៤៖** ឧទាហរណ៍អំពីការអនុវត្តល្អនៃការធ្វើផែនការទីក្រុងបែបបរិយាប័ន គម្រោង Aeon Mall រាជធានីភ្នំពេញ។ ប្រភព៖ Christina Karagianni (២០២៤)។



**រូបភាពទី ៥៖** ផ្លូវថ្មើរជើង ត្រូវបានរចនាតូចពេក មិនអាចអនុញ្ញាតឲ្យម្តាយម្នាក់ជាមួយនឹងរទេះទារក និងមិត្តរបស់នាងដើរជាប់គ្នាបាន។ ឧទាហរណ៍ពីទីក្រុងភ្នំពេញ។ ប្រភព៖ Michael Waibel (២០២២)។

*ការណែនាំ*

កង្វះតំណាងគ្រប់គ្រាន់របស់ស្ត្រី និងមនុស្សដែលមានពិការភាពក្នុងវិស័យស្ថាបត្យកម្មសំណង់ និងការធ្វើផែនការទីក្រុង បណ្តាលឲ្យខ្វះភាពចម្រុះនៃទស្សនៈនិងតម្រូវការ។ កត្តានេះអាចបង្កការខាតបង់ដល់មនុស្សទាំងនេះ ដែលបណ្តាលមកពីកង្វះចន្លោះ ដែលការខូចខាតនោះរួមមានអគារ ឬទ្រព្យសាធារណៈ ដែលមិនដំណើរការប្រកបដោយប្រសិទ្ធភាព និងមិនមានផាសុខភាពសម្រាប់ស្ត្រី ឬមានឧបសគ្គជារូបវ័ន្ត ដែលរារាំងការប្រើប្រាស់សម្រាប់មនុស្ស ដែលពិបាកធ្វើដំណើរ ឬអ្នកមានពិការភាពផ្សេងៗ។

ទីក្រុងមួយមានបរិយាប័ន ត្រូវការនូវការចូលរួមប្រកបដោយបរិយាប័ន។ នេះមានន័យថា គ្រប់ៗគ្នាត្រូវតែប្តេជ្ញាចិត្តចូលរួមយ៉ាងសកម្ម និងមាន-ន័យសម្រាប់ស្ត្រី ក្មេងស្រី និងក្រុមអ្នកដែលមានអត្តសញ្ញាណផ្លូវភេទ និងភេទខុសៗគ្នា ព្រមទាំងមនុស្ស ដែលមានពិការភាព។

ការរចនាទីក្រុងមានសក្តានុពលក្លាយជាចលករយ៉ាងសំខាន់ សម្រាប់សមភាពសង្គម។ ប្រសិនបើរៀបចំវិធីសាស្ត្រចូលរួមយ៉ាងប្រុងប្រយ័ត្ន នោះអាចបង្កើនបរិយាប័ន ភាពគ្មានការរារាំង សុវត្ថិ-ភាព ភាពអាចបត់បែនបាន ការយកចិត្តទុកដាក់ពីវប្បធម៌ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ។

ជាចុងក្រោយ ការរួមបញ្ចូលផ្នែកនៃយេនឌ័រគឺជាឱកាសមួយ ដែលផ្តល់អត្ថប្រយោជន៍ជាច្រើន។ ដូច្នេះវាមានសារៈសំខាន់នៅក្នុងការបង្កើតវេទិកាដើម្បីឲ្យមានសំឡេងចម្រុះបានចូលរួម។ តម្រូវការបំណងប្រាថ្នា ចំណេះដឹង និងជំនាញរបស់ពួក-គេ គឺជាធាតុចូលដ៏មានតម្លៃសម្រាប់ស្ថាបត្យករ អ្នកធ្វើផែនការទីក្រុង អ្នករចនា និងទីក្រុងទាំង-មូល។

*គោលការណ៍*

**បរិយាប័ន៖** បង្កើតកន្លែង ដែលអាចទទួលបានភេទចម្រុះ ដើម្បីធានាមនុស្សគ្រប់រូបមានអារម្មណ៍ថាត្រូវបានស្វាគមន៍ និងគិតគូរជារួម។

**ភាពងាយស្រួលក្នុងការប្រើប្រាស់៖** ធានាបានថាមនុស្សគ្រប់រូប អាចប្រើប្រាស់បានងាយស្រួល ដោយពិចារណាទៅលើសមត្ថភាពរាងកាយ និងតម្រូវការខុសៗគ្នា។

**សុវត្ថិភាព៖** ផ្តល់អាទិភាពដល់សុវត្ថិភាព ដោយដោះស្រាយបញ្ហាដូចជាភ្លើងបំភ្លឺ ការមើលឃើញ និងវិធានការសុវត្ថិភាព ដែលមានអត្ថប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ទាំងអស់។

**ភាពទន់ភ្លន់៖** រចនាកន្លែង ដែលអាចបត់បែនទៅតាមគោលបំណងផ្សេងៗ ឬតម្រូវការកំពុងនឹងផ្លាស់ប្តូរដើម្បីបង្កើនចម្រុះភាព និងប្រសិទ្ធភាព។

**ការចូលរួម៖** អញ្ជើញភាគីពាក់ព័ន្ធចម្រុះចូលរួមក្នុងការអភិវឌ្ឍន៍សហគមន៍ ដោយពិចារណាលើការចូលរួម និងទស្សនៈរបស់ពួកគេ ដើម្បីបង្កើតទីតាំងប្រកបដោយបរិយាប័នកាន់តែប្រសើរ។

**សមភាព៖** ធានាថា នឹងមានការចូលដំណើរការយ៉ាងស្មើគ្នា និងយុត្តិធម៌ចំពោះទ្រព្យ និងសេវាសាធារណៈ និងសម្ភារៈ ដោយមិនគិតអំពីអត្ត-សញ្ញាណភេទ ឬប្រភពដើមនៃអ្នកប្រើប្រាស់ រួមទាំងការយកទៅទូទាត់ស្មើគ្នារវាងបុរស និងស្ត្រីដែលមានការងារដូចគ្នា។

**ភាពជាតំណាង៖** បង្ហាញទស្សនៈវប្បធម៌ និងបទដ្ឋានពាក់ព័ន្ធទៅនឹងអត្តសញ្ញាណយេនឌ័រដោយទទួលស្គាល់ គោរពប្រភពដើម និងបទ-ពិសោធន៍ចម្រុះ។

**ការរចនារួមគ្នា៖** អញ្ជើញបុរស និងស្ត្រីឲ្យចូលរួមស្មើភាពគ្នាក្នុងដំណើរការធ្វើសេចក្តីសម្រេច និងការរចនា។



ការផ្លាស់ប្តូរតុនៅក្នុងបន្ទប់ទឹករបស់ស្ត្រីតែប៉ុណ្ណោះ ប៉ុន្តែមិននៅក្នុងបន្ទប់ទឹករបស់បុរស ពង្រឹងបទដ្ឋាន និងគំរូ ហើយធ្វើឱ្យការបែងចែកឡើងវិញនៃការងារថែទាំស្មើរតែមិនអាចទៅរួចទេ។



កង្វះលទ្ធភាពទទួលបាន គឺជាបញ្ហាប្រឈមពិសេសមួយសម្រាប់មនុស្ស ដែលបំពេញការងារថែទាំ។



សម្រាប់អ្នកថ្មើរជើងមួយចំនួន ការចោលសំរាមអាចជាបញ្ហាប្រឈមនៃការចល័តពិតប្រាកដ។

**រូបភាពទី ៦៖** ក្រាហ្វបង្ហាញពី កង្វះខាតទាក់ទងនឹងការរចនាអគារ និងទីក្រុងប្រកបដោយបរិយាប័ន្ន។ ប្រភព: រក្សាសិទ្ធិដោយ Mary Dellenbaugh-Losse, urban.policy។

## ការធ្វើឲ្យទ្រព្យសាធារណៈកាន់តែមានបរិយាប័ន តាមរយៈ

*រង្វាយតម្លៃក្រោយពីការប្រើប្រាស់*

បុរស ស្ត្រី អ្នកមានអត្តសញ្ញាណភេទចម្រុះ និងមនុស្ស ដែលមានសមត្ថភាពខុសៗគ្នាមានទំនោរប្រើប្រាស់ទ្រព្យសាធារណៈ តាមរបៀបខុសៗគ្នា។ ដើម្បីគាំទ្រការធ្វើផែនការ ដែលមានបរិយា-ប័នរួមអោយកាន់តែសកម្ម BUILD4PEOPLE បានលើកស្ទួយឱ្យប្រើប្រាស់ វិធីសាស្ត្ររង្វាយតម្លៃក្រោយការប្រើប្រាស់។ POE គឺជាដំណើរការដែលអនុញ្ញាតវាយតម្លៃលទ្ធផល និងប្រសិទ្ធភាពនៃបរិយាកាស ដែលកសាងឡើងដូចជាទ្រព្យសាធារណៈ។ គន្លឹះសំខាន់នៃវិធីសាស្ត្រនេះ គឺការទទួលយកទស្សនៈពីអ្នកប្រើប្រាស់។ តាមរយៈវិធីនេះ គេអាចសិក្សាបានថា បរិយាកាសនោះបានបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ និងគាំទ្រដល់សកម្មភាពរបស់ពួកគេនៅកន្លែងនោះកម្រិតណា ដោយមិនគិតតែគុណប្រយោជន៍នៃការរចនាប្លង់តែមួយនោះទេ។

POE អាចខុសគ្នាទៅតាមវិសាលភាព និងសេចក្តីលម្អិត។ ជាទូទៅត្រូវបានចែកចេញជាបីប្រភេទសំខាន់ៗ ដោយផ្អែកលើជម្រៅ និងស្មុគស្មាញនៃការប្រើប្រាស់ (មើលរូបភាព៧)៖ ១. សញ្ញាណគោល(១–២ ថ្ងៃ) ២. ការតាមដាន (១៦០–២៤០ ម៉ោង) ៣. ការវិភាគ (រយៈពេលជាច្រើនឆ្នាំ)។ សញ្ញាណគោលផ្តល់នូវការវាយតម្លៃដំបូងយ៉ាងឆាប់រហ័ស និងមានតម្លៃទាប ខណៈដែលការតាមដានមានកម្រិតជ្រៅជាង ដោយប្រើប្រាស់បទសម្ភាសន៍មានក្របខណ្ឌ និងការវាស់វែង-ជាក់លាក់។ ការតាមដាន គឺជាវិធីសាស្ត្រពេញ-លេញ និងស្មុគស្មាញបំផុត។ វិធីសាស្ត្រស្នូលរបស់ POE គឺការសម្ភាសន៍ពីម្នាក់ទៅម្នាក់ ផ្អែកលើការសាកសួរអ្នកប្រើប្រាស់អំពីតម្រូវការ និងបទពិសោធន៍របស់ពួកគេ ក្នុងពេលវេលាជាក់លាក់ដែលអ្នកឆ្លើយតប អាចផ្តល់មតិយោបល់មានតម្លៃអំពីរបៀបដែលកន្លែងនោះបានបំពេញតម្រូវការរបស់ពួកគេ។ ការភ្ជាប់រវាងការធ្វើផែនការ និងជំនាញរបស់អ្នកប្រើប្រាស់ អាចផ្តល់-ព័ត៌មានសំខាន់សម្រាប់គម្រោងអនាគត និងគាំទ្រការអភិវឌ្ឍបរិយាកាស ដែលផ្តោតលើអ្នកប្រើប្រាស់មានប្រសិទ្ធភាព និងមានចីរភាពកាន់តែប្រសើរ។







**រូបភាពទី ៧ និង៨៖** ឧទាហរណ៍នៃប្រភេទ POE ។ ប្រភព៖ រៀបចំដោយគម្រោង (គូសដោយ A. Hütte) ។

# រមៀបរស់នៅមានចីរភាព

12 RESPONSIBLE CONSUMPTION AND PRODUCTION
11 SUSTAINABLE CITIES AND COMMUNITIES




**រូបភាពទី ៩៖** ទម្រង់ផ្សេងៗនៃអាកប្បកិរិយាប្រកបដោយចីរភាព។
ប្រភព៖ Own Design ។




**រូបភាពទី ១០៖** យុទ្ធនាការទីផ្សារសង្គមឆ្លុះបញ្ចាំងពីភាពចម្រុះនៃអាកប្បកិរិយា។
ប្រភព៖ Own Design ។

*ការណែនាំ*

បរិវត្តកម្មក្រុងប្រកបដោយចីរភាព ត្រូវការការចូលរួមពីភាគីពាក់ព័ន្ធជាច្រើនរួមមាន អ្នកកំណត់គោលនយោបាយ អ្នកធ្វើផែនការ ស្ថាបត្យករ និងអ្នកបច្ចេកទេស។ ដូចគ្នានេះផងដែរ ប្រជាពលរដ្ឋក្នុងទីក្រុងអាចចូលរួមក្នុងដំណើរការនេះ ដោយចែករំលែកទស្សនៈរបស់ពួកគេក្នុងដំណើរការធ្វើផែនការ។ ទោះជាយ៉ាងណា ជាញឹកញាប់តែងតែត្រូវបានមើលរំលងលើការ ចូលរួមរបស់ពលរដ្ឋសម្រាប់ការផ្លាស់ប្តូរនេះ និងទទួលយកនូវរបៀបរស់នៅមានចីរភាព និងអនុវត្តអាកប្បកិរិយា ដែលគាំទ្របរិស្ថានក្នុងវិបទឯកជនភាពរបស់គេ។ អាកប្បកិរិយាទាំងនេះអាចមានទម្រង់ផ្សេងៗ៖ មនុស្សអាចអនុវត្តអាកប្បកិរិយាបរិស្ថានប្រចាំថ្ងៃ (ដូចជា ការជិះកង់ ឬការជៀសវាងការចំណាយពេលមិនបានការ) ធ្វើការវិនិយោគក្នុងបច្ចេកវិទ្យាបៃតង (ឧ. បំពាក់បន្ទះសូឡានៅតាមផ្ទះ សូមមើល Deuß et al., ២០២៥) និងផ្សព្វផ្សាយការយល់ដឹងអំពីអាកាសធាតុ និងបទដ្ឋាននៅក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេឧទាហរណ៍ ក្នុងចំណោមមិត្តភក្តិ និងគ្រួសារ-(Nielsen et al., ២០២៤)។
អាកប្បកិរិយាទាំងអស់ មានមូលដ្ឋានរួមគ្នា៖ មនុស្សមានតម្លៃអេកូឡូស៊ីមានការយល់ដឹងអំពីបញ្ហាបរិស្ថាន (ឧ.ការទទួលស្គាល់ថាការប្រែប្រួលអាកាសធាតុមានឥទ្ធិពលអវិជ្ជមានទៅលើគុណភាពជីវិតរបស់គេ) និងមានអារម្មណ៍ថាខ្លួនអាច និងមានកាតព្វកិច្ចក្នុងការទប់ស្កាត់បញ្ហាទាំងនេះ (Steg & Nordlund, ២០១២)។ លើសពីនេះ ប្រសិនអ្នកនៅជុំវិញយើងអនុវត្តអាកប្បកិរិយាដែលគាំទ្របរិស្ថាន នោះវានឹងអាចជំរុញឲ្យយើងទទួលយករបៀបរស់នៅមានចីរភាពផ្ទាល់ខ្លួនផងដែរ។
ជាពិសេស ការពាក់ព័ន្ធនៃវិស័យទាំងនេះអាចខុសគ្នាតាមអាកប្បកិរិយា។ ដូច្នេះប្រសិនបើចង់គាំទ្រសហគមន៍ឲ្យទទួលយករបៀបរស់នៅមានចីរភាព វាមានសារៈសំខាន់ក្នុងការប្តេជ្ញាចិត្តប្រឹងប្រែងចាត់ចែងឲ្យសមស្របទៅនឹងអាកប្បកិរិយាជាក់លាក់ ដែលគម្រោងចង់លើកស្ទួយ។ វាអាចសម្រេចបានតាមរយៈយុទ្ធនាការទីផ្សារសង្គម (Lee & Kotler, ២០១៥)។
ទោះបីជាការយល់ដឹងអំពីបញ្ហាជាសារៈសំខាន់សម្រាប់អាកប្បកិរិយាបរិស្ថាន ការផ្តល់ចំណេះដឹង និងលើកកម្ពស់ការយល់ដឹងរបស់មនុស្សម្នាក់ៗក្តី តែវាមិនគ្រប់គ្រាន់ដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរប្រកបដោយអត្ថន័យទេ។ ទោះបីមនុស្សដឹងអំពីបញ្ហាបរិស្ថានដែលបណ្តាលមកពីអាកប្បកិរិយាសង្គមក៏ដោយ វាមិនមានន័យថាពួកគេនឹងផ្លាស់ប្តូរអាកប្បកិរិយាដោយស្វ័យប្រវត្តិឡើយ។ ពួកគេ ត្រូវការលក្ខខណ្ឌរចនាសម្ព័ន្ធគាំទ្រ ដែលអាចអនុញ្ញាតឲ្យពួកគេទទួលយកការផ្លាស់ប្តូរឥរិយាបទប្រកបដោយចីរភាព។ វិស័យទាំងនេះ ត្រូវតែបានគិតគូរក្នុងពេលព្យាយាមលើកស្ទួយរបៀបរស់នៅមានចីរភាពក្នុងចំណោមប្រជាពលរដ្ឋទីក្រុង។

QR code to
Build4People
Online Exhibition




**រូបភាពទី ១១៖** ឧទាហរណ៍ពីក្រុមអ្នកអនុវត្តបៃតងដកស្រង់ពី Youtube របស់ B4P ។
ប្រភព៖ Build4People

## ក្រុមអ្នកត្រួសត្រាយបៃតងនៅកម្ពុជា

*ឧទាហរណ៍ល្អៗ*
*នៃយុទ្ធនាការសង្គម*

ផលអវិជ្ជមានពីការរីកចម្រើននៅរាជធានីភ្នំពេញ គឺជាការកើនឡើងនៃដានជើងបរិស្ថាន និងការបំផ្លាញបរិស្ថានកាន់តែខ្លាំងដោយមានការបង្ហាញច្បាស់នូវការបាត់បង់តំបន់បៃតង និងអាងទឹក ការកើនឡើងនៃការបំពុលខ្យល់ ការកកស្ទះចរាចរណ៍ញឹកញាប់ និងបញ្ហាផ្សេងៗទៀតទាក់ទងនឹងសំណល់។

ក្នុងបរិបទនេះ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីបញ្ហាទាំងនេះ ក្លាយជាបរិបទពិភាក្សាដ៏សំខាន់។ ទោះយ៉ាងណាសង្គម និងឥទ្ធិពលសង្គម មានតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅដល់សហគមន៍ និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឥរិយាបទទៅរករបៀបនៃការរស់នៅ ប្រកបដោយចីរភាព-(GRISKEVICIUS, CIALDINI, & GOLDSTEIN , ២០០៨)។ ជាពិសេស ការបង្ហាញឧទាហរណ៍វិជ្ជមាននៃអាកប្បកិរិយាបរិស្ថានអាចជួយជម្រុញយន្តការសង្គមទាំងនេះ។ ការប្រើប្រាស់បទដ្ឋានសង្គមតាមរបៀបនេះធ្វើឱ្យអាកប្បកិរិយាបរិស្ថានកាន់តែមានសក្តានុពល និងងាយស្រួលសម្រាប់សាធារណជនទូទៅ។

បច្ចុប្បន្ននេះ មានអ្នកត្រួសត្រាយអាកប្បកិរិយាដែលគោរពបរិស្ថានមួយចំនួននៅកម្ពុជា។ ការដែលដោយផ្តល់ឱ្យពួកគេនូវភាពលេចធ្លោរ និងការទទួលស្គាល់ជាសាធារណៈ ពួកគេអាចក្លាយជាគំរូល្អ ដើម្បីលើកទឹកចិត្តប្រជាជនទីក្រុងឱ្យអនុវត្តអាកប្បកិរិយាប្រកបដោយចីរភាព។

ជាផ្នែកមួយនៃយុទ្ធសាស្ត្រយុទ្ធនាការធំទូលាយ គម្រោង BUILD4PEOPLE បានបង្កើតនិងចេញផ្សាយពិព័រណ៍តាមអ៊ីនធឺណិតតាមរយៈឆានែល YOUTUBE របស់ BUILD4PEOPLE ដោយលើកកម្ពស់ឥទ្ធិពលសង្គមតាមរយៈការពន្យល់បកស្រាយពីបទដ្ឋានសង្គមជាគំរូ៖ យុទ្ធនាការ "អ្នកត្រួសត្រាយបៃតងកម្ពុជា"។

យុទ្ធនាការនេះ មានគោលបំណងបង្កើននូវភាពលេចធ្លោរ របស់ក្រុមអ្នកត្រួសត្រាយដោយចីរភាពទាំងអស់ ដើម្បីលើកទឹកចិត្តអ្នកផ្សេងទៀតនៅទីក្រុងឱ្យអនុវត្តរបៀបរស់នៅប្រកបដោយភាពរាក់ទាក់។ ដោយបង្ហាញគំរូទាំងនេះ យុទ្ធនាការនេះបានចូលរួមក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាជននៅទីក្រុងនៃប្រទេសកម្ពុជា និងជួយបង្កើត របៀបរស់នៅប្រកបដោយចីរភាពដែលជាបទដ្ឋានសង្គមរួម។

សេចក្តីណែនាំ ០២.៦

# III ការផ្ដួចផ្ដើម




**រូបភាពទី ១២៖** ស្លាកសញ្ញា ECTL តាមរយៈពេលកន្លងមក បង្ហាញពីការចូលរួមកាន់តែច្រើនរបស់ភាគីពាក់ព័ន្ធក្នុងគម្រោង។
ប្រភព៖ Build4People ។





**រូបភាពទី ១៣៖** ទស្សនៈពីការងារក្រុមតាមប្រធានបទក្នុងកំឡុងពេល ECTL 2024 ។
ប្រភព៖ Build4People ។

## មន្ទីរពិសោធន៍ពីការរស់នៅក្នុងទីក្រុង

*ស៊េរីមន្ទីរពិសោធន៍ផ្លាស់ប្ដូរទៅកាន់ទីក្រុងអេកូរបស់គម្រោង B4P*

*គោលបំណង និងដំណើរការ*

មន្ទីរពិសោធន៍ ផ្លាស់ប្ដូរទៅកាន់ទីក្រុងអេកូនៃគម្រោង Build4People គាំទ្រការផ្លាស់ប្ដូរទៅកាន់ទីក្រុងប្រកបដោយចីរភាព តាមរយៈវិធីសាស្ត្រចូលរួមការចូលរួមជាសហគមន៍ និងវិធីសាស្ត្រចម្រុះវិស័យ។ ដើម្បីឆ្លើយតប ទៅនឹងការរីកចម្រើនរហ័សនៃរាជធានីភ្នំពេញ ECTL ផ្ដល់វេទិកាសហការ ដែលមានភាគីពាក់ព័ន្ធចម្រុះ ដើម្បីកំណត់បញ្ហាបង្កើតចក្ខុវិស័យរួម នឹងរចនាយុទ្ធសាស្ត្រ ដែលងាយអនុវត្តស្របតាមការអភិវឌ្ឍតំបន់ជាយទីក្រុងប្រកបដោយចីរភាព។

ECTL មួយៗដំណើរការយ៉ាងសកម្មរយៈពេលមួយសប្ដាហ៍ ដែលមានប្រាំដំណាក់កាល៖ (១) ទស្សនកិច្ចនៅទីតាំង (២) សន្និសីទបើកការងារ (៣) សិក្ខាសាលាចូលរួម ដើម្បីកំណត់បញ្ហាសំខាន់ នឹងបង្កើតចក្ខុវិស័យរួម (៤) ការងារក្រុមតាមប្រធានបទ ដើម្បីស្វែងរកដំណោះស្រាយ និង (៥) សន្និសីទបង្ហាញលទ្ធផល។ ចំណុចសំខាន់នៃវិធីសាស្ត្រនេះគឺ “សិក្ខាសាលាចក្ខុវិស័យ” (Perspektivenwerkstätten) ដែលជាវិធីសាស្ត្រចូលរួម និងផ្អែកលើការឯកភាពសម្រាប់ការធ្វើផែនការសមាហរណកម្ម។ វាត្រូវបានណែនាំជាលើកដំបូងនៅអាល្លឺម៉ង់ឆ្នាំ១៩៩៥ ដោយ Andreas von Zadow និងផ្អែកលើ “ក្រុមជំនួយរចនាទីក្រុង” របស់សហរដ្ឋអាមេរិក (១៩៦៧)។ វិធីសាស្ត្រនេះលើកទឹកចិត្តការពិភាក្សារវាងភាគីពាក់ព័ន្ធចម្រុះ រួមមានប្រជាពលរដ្ឋ អ្នករៀបចំផែនការ អ្នកវិនិយោគ អ្នកនយោបាយ នឹងសហគមន៍។

*ECTL ២០២០*

ត្រូវបានរៀបចំក្នុងដំណាក់កាលកំណត់គម្រោង ដើម្បីចាប់ផ្ដើមការចូលរួមរបស់ភាគីពាក់ព័ន្ធ និងកសាងទំនុកចិត្តជាមួយសហគមន៍ក្នុងតំបន់។ វាបានដោះស្រាយបញ្ហាទីក្រុងដូចជា កង្វះតំបន់បៃតង ការដឹកជញ្ជូនសាធារណៈមិនមានប្រសិទ្ធភាព និងការបែងចែកសង្គមដោយសាររបៀបរស់នៅតាមបែបបុរី។ កិច្ចការរួមនេះ បានបង្កើតផែនការមេមួយផ្នែកឈ្មោះថា ទុកអោយមានលំហូរតាមធម្មជាតិ ដែលណែនាំគំនិត “ទីក្រុងបៃតង-ខៀវ” ដោយរួមបញ្ចូលការគ្រប់គ្រងទឹកភ្លៀង ការចល័ត និងហេដ្ឋារចនាសម្ព័ន្ធបរិស្ថាន ដែលជាការចាប់ផ្ដើមនៃ វិធីសាស្ត្រធ្វើផែនការចម្រុះវិស័យថ្មីមួយនៅភ្នំពេញ។

*ECTL ២០២២*

ECTL-២០២២ បានពង្រីកការចូលរួមទៅកាន់ភាគីពាក់ព័ន្ធថ្នាក់ជាតិនិងកម្រិតទីក្រុង ដើម្បីកែលម្អចក្ខុវិស័យឆ្នាំ២០២០ តាមរយៈប្រធានបទសំខាន់៥៖ ចរាចរណ៍ ទឹក ក្របខណ្ឌច្បាប់ ការអភិវឌ្ឍន៍ទីក្រុង និងសមាហរណ៍កម្មការរៀបចំដែនដី។ គំនិត “សមាហរណកម្មតំបន់ទីក្រុង” បានកើតឡើង ដោយផ្ដោតលើការភ្ជាប់បុរីជាមួយប្រព័ន្ធទីក្រុង និងបរិស្ថានជុំវិញដើម្បីលើកកម្ពស់ភាពសុខដុម និងភាពរស់រវើកក្នុងសហគមន៍។

*ECTL ២០២៣*

ការវិវដ្ដនេះ បានសម្គាល់ជាការផ្លាស់ប្ដូរទៅរកការសហការជាមួយវិស័យឯកជន ដោយចូលរួមជាមួយក្រុមហ៊ុនបុរីប៉េងហួត។ ការសិក្សាតាមរយៈទីក្រុងអេកូ បានវាយតម្លៃគំនូរប្លង់បុរី បទអន្តរាគមន៍បន្ថែម និងមានគោលបំណងធ្វើឱ្យការអភិវឌ្ឍឯកជនស្របតាមស្តង់ដាររចនាបែបសមាហរណកម្ម និងប្រកបដោយចីរភាព។

*ECTL ២០២៤*

បានសហការជាមួយក្រុមហ៊ុន OCIC ដើម្បីស្វែងរកការអភិវឌ្ឍតំបន់មាត់ច្រាំងទន្លេ ដោយផ្ដោតលើរបៀងអេកូឡូស៊ី ការទប់ទល់ទឹកជំនន់ និងតំបន់សាធារណៈ។ ការសិក្សាបានជំរុញការអនុវត្តជាក់ស្ដែងនៃវិធីសាស្ត្រ ECTL ក្នុងបរិបទទីក្រុងបែបសមាហរណកម្មនៅជាយក្រុងភ្នំពេញ ដែលប្រឈមការផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស។

*សន្និដ្ឋាន*

ក្នុងរយៈពេល ៤ ដងនៃការបោះពុម្ភ ការធ្វើការសាកល្បងរួមគ្នាតាមរយៈ B4P-ECTL បានអភិវឌ្ឍទៅជាវេទិកាធ្វើផែនការ ដែលមានសកម្មភាពរស់រវើក ដើម្បីលើកកម្ពស់ការសហការចម្រុះវិស័យ និងអន្តរវិស័យ កសាងសមត្ថភាពក្នុងប្រទេស និងអនុវត្តគោលការណ៍ចីរភាពតាមរយៈការរចនាតាមបែបសមាហរណកម្ម។ ដោយអនុវត្តវិធីសាស្ត្រ ដែលមានស្ថិរភាព ប៉ុន្តែមានលក្ខណៈទន់ភ្លន់ ECTL បានបង្ហាញថាគោលគំនិតទ្រឹស្ដី អាចបម្លែងទៅជាដំណោះស្រាយជាក់ស្ដែង ទៅតាមស្ថានភាពចម្រុះរបស់តំបន់ទីក្រុង។ គម្រោងបានផ្លាស់ប្ដូរខណ្ឌច្បារអំពៅទៅជា ករណីសិក្សាជីវិតនៃការផ្លាស់ប្ដូរទីក្រុង ដែលមានលក្ខណៈសមាហរណកម្ម និងផ្ដល់ចក្ខុវិស័យ និងជម្រើសផ្សេងៗដល់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។




**រូបភាពទី ១៤៖** ទស្សនៈពីសន្និសីទបើកគម្រោង B4P ECTL ឆ្នាំ២០២៣ ។
ប្រភព៖ Build4People ។







**រូបភាពទី ១៥៖** ឧទាហរណ៍រូបភាពសង្ខេបពីដំណើរការ ECTL កន្លងមក។
ប្រភព៖ Build4People ។


សេចក្តីណែនាំ ០២.៦







រូបភាពទី ១៦៖ ទស្សនៈពីអគារចីរភាព Build-4People ដំបូងនៅឆ្នាំ ២០២២។
ប្រភព៖ Michael Waibel (២០២២) ។

## អន្តរការនៃបទអន្តរាគមន៍តាមរយៈអភិបាលកិច្ច

*វេទិកាផ្នែកសាងសង់នៃគម្រោង B4P*

*គោលបំណង*

គោលបំណងនៃវេទិការផ្នែកសាងសង់ ប្រកបដោយចីរភាព Build4People (SBA) គឺការរួមបង្កើតចក្ខុវិស័យ និងយុទ្ធសាស្ត្រជាមួយអ្នកដឹកនាំដោយចីរភាពក្នុងវិស័យសំណង់នៅរាជធានីភ្នំពេញ។
ការស្រាវជ្រាវកន្លងមកបានបង្ហាញថា មិនមានវេទិកាជាផ្លូវការដើម្បីផ្លាស់ប្តូរព័ត៌មាន សម្រាប់អ្នកសាងសង់ឆ្នើមនៅឡើយទេ។ ការគៀងគងបុគ្គលទាំងនេះ មកជួបជុំគ្នាក្នុងដំណើរការរួម-មួយ នឹងជួយពង្រឹងបណ្តាញ និងសមត្ថភាពសហការរបស់ពួកគេ ហើយគឺជាចំណុចចាប់-ផ្តើមដ៏មានសក្តានុពល។

*ដំណើរការ*

ដោយអនុវត្តទម្រង់គ្រប់គ្រងបរិវត្តកម្ម ដែលបានរៀបចំជាពិសេសដោយគម្រោង Build4People សម្រាប់បរិបទរាជធានីភ្នំពេញ (Jayaweera et al., 2023; Jayaweera et al., ២០២២) វេទិកាសាងសង់ប្រកបដោយចីរភាព (SBA) បានអនុវត្តវិធីសាស្ត្របីជំហាន ដែលផ្តោតលើសំណួរដូចខាងក្រោម (Jayaweera & Waibel, ២០២៤)៖

អ្វីទៅជាបញ្ហានៅក្នុងវិស័យសំណង់ និងអភិវឌ្ឍទីក្រុងបច្ចុប្បន្ននៅរាជធានីភ្នំពេញ?
តើយើងចង់ឱ្យអគារ និងសង្កាត់ទាំងអស់ត្រូវ-បានរចនាសាងសង់ និងដំណើរការយ៉ាងដូចម្តេចនៅរាជធានីភ្នំពេញនៅក្នុងឆ្នាំ ២០៤០? តើយើងអាចឈានទៅសម្រេចតាមគោលដៅអនាគតដែលយើងប្រាថ្នាបានដោយរបៀបណា?

*សិក្ខាសាលា SBA ដំណាក់កាលទី ១៖ បញ្ហាប្រឈមនៃបរិវត្តកម្ម/ ការកំណត់បញ្ហា*

ដំណាក់កាលទី១ នៃ SBA មានគោលបំណងក្នុងការរួមកំណត់ ក្របខណ្ឌបញ្ហាប្រឈមនៃបរិវត្តកម្ម។ សំណួរណែនាំសំខាន់នៃដំណាក់-កាលនេះគឺ៖ តើអ្វីជាបញ្ហានៅក្នុងវិស័យសំណង់ និងអភិវឌ្ឍទីក្រុងបច្ចុប្បន្ននៅរាជធានីភ្នំពេញ? ការកំណត់ក្របខណ្ឌនៃបញ្ហាប្រឈមនៃបរិវត្ត-កម្ម រួមមានការកំណត់បញ្ហា ការបកស្រាយ ការរៀបចំតាមបញ្ហាអាទិភាព និងការរួមបញ្ចូលនៃបញ្ហាទាំងនេះក្នុងប្រធានបទតាមផ្នែកៗ។ ក្នុងក្រុមតូចៗ អ្នកចូលរួមបានគិតពិចារណារៀងៗខ្លួនជាមុនសិន ហើយបន្ទាប់មកទៀតចែករំលែកគំនិតរបស់ពួកគេទៅកាន់អ្នកចូលរួមទាំងអស់។

*សិក្ខាសាលា SBA ដំណាក់កាលទី ២៖ ការបង្កើតចក្ខុវិស័យរួម*

នៅក្នុងដំណាក់កាលទី២ អ្នកចូលរួមបានរួមគ្នាបង្កើត ឬបង្ហាញអាទិភាពសំខាន់ៗ និងគោល-ការណ៍សម្រាប់ពេល អនាគតដែលពួកគេរំពឹងទុកចំពោះប្រព័ន្ធសំណង់ និងអភិវឌ្ឍទីក្រុងក្នុងខណ្ឌ សង្កាត់។ ពួកគេក៏បានបង្ហាញនូវទិដ្ឋភាពនិងរឿងរ៉ាវនៃអនាគត ដែលគេចង់បាននៅក្នុងចក្ខុវិស័យរួមគ្នា។ សំណួរណែនាំសំខាន់គឺ៖ តើយើងចង់ឱ្យអគារ និងសង្កាត់ត្រូវបានរចនាសាង-សង់ និងដំណើរការយ៉ាងដូចម្តេចនៅរាជធានីភ្នំពេញក្នុងឆ្នាំ ២០៤០? ក្នុងដំណាក់កាលមុនៗអ្នកចូលរួមបានគិតពិចារណារៀងៗខ្លួនជាមុនសិនហើយបន្ទាប់មកពិភាក្សាគំនិតក្នុងក្រុមតូចៗ ហើយចុងក្រោយ បានពិភាក្សារួមក្នុងកិច្ចប្រជុំទូទៅ។

*សិក្ខាសាលា SBA ដំណាក់កាលទី៣៖ ការអភិវឌ្ឍរបៀបវារៈបរិវត្តកម្ម*

ក្នុងដំណាក់កាលទី៣នៃ SBA វិធីសាស្ត្រ back-casting ត្រូវបានប្រើដើម្បីភ្ជាប់សេណារីយ៉ូ និងរឿងរ៉ាវអនាគតជាមួយបញ្ហាបច្ចុប្បន្ន ដើម្បីអភិវឌ្ឍផ្លូវ និងយុទ្ធសាស្ត្រនៃបរិវត្តកម្មជាក់ស្តែង។ នៅទីនេះ សេចក្តីព្រាងដំបូងនៃ “របៀបវារះបរិវត្តកម្ម” ត្រូវបានបង្កើត។ សំណួរណែនាំសំខាន់ សម្រាប់ជំហាននេះគឺ៖ “តើយើងអាចឈានទៅកាន់អនាគតដែលយើងប្រាថ្នាបានដោយរបៀបណា? តើត្រូវធ្វើសកម្មភាពអ្វីខ្លះក្នុងរយៈពេលខ្លី មធ្យម និងវែង?”

*សេចក្តីសន្និដ្ឋាន*

ជាសរុប សិក្ខាសាលា SBA ដំបូងរបស់ Build-4People គឺជាមន្ទីរពិសោធន៍នៃបរិវត្តកម្មទីក្រុងដ៏ជោគជ័យមួយនៅប្រទេសកម្ពុជា។ គម្រោងបានអញ្ជើញអ្នកដឹកនាំ និងភ្នាក់ងារនៃបរិវត្តកម្មចម្រុះពីវិស័យសំណង់ប្រកបដោយចីរភាព និងអភិវឌ្ឍទីក្រុងមកពិភាក្សា។ ជាស្ថាប័នមិនផ្លូវការ និងជាអ្នកសហការរួមបង្កើតកិច្ចសហការ SBA បានគាំទ្រការបង្កើតតំណភ្ជាប់ថ្មីរវាងបុគ្គលទៅនិងបណ្តាញដែលមានភាពរឹងមាំ និងចាប់ផ្តើមការពិភាក្សាគ្នាលើចំណុចប្រទាក់រវាងវិទ្យាសាស្ត្រ នយោបាយ អាជីវកម្ម និងសង្គមស៊ីវិល។
ក្នុងពេល ដែលអ្នកចូលរួមភាគច្រើនយល់ស្របថា បរិវត្តកម្មទៅរកទីក្រុងប្រកបដោយចីរភាពគឺជាការចាំបាច់ហើយ SBA អាចបង្កើតផលជះវិជ្ជមានដែលការងារនេះ អាចសម្រេចបានលុះត្រាតែគេរក្សារដំណើរការចូលរួមរយៈពេលវែងប៉ុណ្ណោះ។ (Jayaweera & Waibel, ២០២៤)។




រូបភាពទី ១៧៖ រូបភាពសង្ខេបនៃដំណាក់កាលទី៣ នៃ SBA៖ បញ្ហាប្រឈមនៃបរិវត្តកម្ម/ការកំណត់ក្របខណ្ឌបញ្ហា ដោយបង្កើតចំណេះដឹងជាប្រព័ន្ធ។
ប្រភព៖ Uddam Pen (២០២២) ។




រូបភាពទី ១៨៖ រូបភាពសង្ខេបនៃដំណាក់កាលទី២ នៃ SBA៖ ការបង្កើតចក្ខុវិស័យរួម ដោយមានគោលបំណងបង្កើតចំណេះដឹងគោលដៅ។
ប្រភព៖ Uddam Pen (២០២២) ។




រូបភាពទី ១៩៖ រូបភាពសង្ខេបនៃដំណាក់កាលទី៣ នៃ SBA៖ ការអភិវឌ្ឍរបៀបវារះបរិវត្តកម្ម ដោយមានគោលបំណងបង្កើតចំណេះដឹងអនុវត្ត។
ប្រភព៖ Uddam Pen (២០២២) ។

សេចក្តីណែនាំ ០២.៦








**រូបភាពទី ២០៖** ផ្នែកមួយនៃការចូលរួមរបស់សាធារណជននាទីតាំងបង្ហាញបណ្ដោះអាសន្ន ដែលរៀបចំនៅកោះនរា។
ប្រភព៖ Michael Waibel (២០២៤) ។

## កំណត់ចក្ខុវិស័យ និងគោលបំណងរួម
*ទីតាំងបង្ហាញបណ្ដោះអាសន្នរៀបចំដោយ THE B4P-SMMR*

*ចក្ខុវិស័យ*

ចក្ខុវិស័យកំណត់អនាគត ដែលសហគមន៍ចង់បានដោយផ្អែកលើតម្លៃស្នូល និងការចូលរួមពីសាធារណជន។ ធាតុសំខាន់ៗនៃការបង្កើតចក្ខុវិស័យ៖

- ពិចារណាធនធាន និងតម្រូវការរបស់សហគមន៍
- មានការចូលរួមពីសាធារណជនដោយចាប់ផ្ដើមពីដំបូង និងបន្តជាបន្តបន្ទាប់
- អាចជាដំណើរការឯករាជ្យ ឬជាផ្នែកមួយនៃការធ្វើផែនការទូលំទូលាយ

*ដំណើរការបង្កើតចក្ខុវិស័យនៅក្នុងប្រទេសកម្ពុជា*

ការបង្កើតចក្ខុវិស័យ គឺជារឿងថ្មីក្នុងការធ្វើផែនការរៀបចំក្រុងនៅប្រទេសកម្ពុជា ដែលត្រូវការដំណើរការតាមដំណាក់កាល៖

- **ដំណាក់កាលទី១៖** ទីតាំងបង្ហាញបណ្ដោះ-អាសន្ននៅតំបន់មាត់ទន្លេកោះនរាបានប្រមូលយោបល់ពីប្រជាពលរដ្ឋ និងភ្ញៀវច្រើនជាង ១000 នាក់។ ការចូលរួមនេះ ត្រូវបានរៀបចំដោយ Build4People, SMMR និង Impact-Hub ដើម្បីស្វែងយល់ពីការចង់បានរបស់-សហគមន៍។
- **ដំណាក់កាលទី២៖** មន្ទីរពិសោធន៍បរិវត្តកម្មទៅកាន់ទីក្រុងអេកូ ដែលរៀបចំដោយ Build-4People បានគៀងគងអ្នករៀបចំគោល-នយោបាយសំខាន់ៗមកជួបជុំគ្នា។ ក្រុមហ៊ុន OCIC បានរំពឹងថានឹងផ្លាស់ប្ដូរ Norea City ទៅជាសង្កាត់រស់រវើក និងមានតម្រូវការខ្ពស់នាពេលអនាគត។

*គោលបំណង*

គោលបំណងជាក់លាក់ និងអាចវាស់វែង បាន-បង្ហាញយ៉ាងច្បាស់ថា តើចក្ខុវិស័យ ដែលបានកំណត់នោះអាចសម្រេចបានដោយរបៀបណា។ គោលបំណងគួរត្រូវបាន៖

- អភិវឌ្ឍជារួម
- កែសម្រួល ដោយផ្អែកទៅលើការចូលរួមពីសហគមន៍ និងការវិភាគទិន្នន័យ (ឧ.តាមរយៈ ទីតាំងបង្ហាញបណ្ដោះអាសន្ន និងលក្ខណវិនិច្ឆ័យប្រកបដោយចីរភាព)
- គាំទ្រដោយសូចនាករ ដែលអាចវាស់វែងបាន (ឧ.លក្ខណវិនិច្ឆ័យប្រកបដោយចីរភាពរបស់គម្រោង Build4People)

*ការកំណត់គោលបំណង សម្រាប់ការអភិវឌ្ឍផ្អែកលើប្រព័ន្ធដឹកជញ្ជូននៅរាជធានីភ្នំពេញ*

គោលបំណង TOD ខុសៗគ្នាតាមតំបន់រួមមានតំបន់ប្រើប្រាស់ចម្រុះ តំបន់អាជីវកម្ម តំបន់ឧស្សាហកម្ម ឬសង្កាត់លំនៅឋាន។ កោះនរាដំណើរការមន្ទីរពិសោធន៍នៃបរិវត្តកម្មទៅកាន់ទីក្រុងអេកូបានជួយកំណត់បញ្ហាសំខាន់ៗ និងឱកាសដែលក្លាយទៅជាមូលដ្ឋាន សម្រាប់ការកំណត់គោល-បំណង TOD។ អ្នករៀបចំផែនការត្រូវកំណត់គោលការណ៍ទូលំទូលាយរបស់ TOD ទៅជាគោលបំណងជាក់លាក់ និងអាចអនុវត្តបាន-ស្របតាមផែនការមេរបស់ទីក្រុង និងអាទិភាពរបស់រាជរដ្ឋាភិបាល។





**រូបភាពទី ២១៖** ទីតាំងបង្ហាញបណ្ដោះអាសន្នដែលរៀបចំនៅកោះនរា។
ប្រភព៖ Sovan Sieng (២០២៤) ។

## ទីតាំងបង្ហាញបណ្ដោះអាសន្នដែលរៀបចំនៅកោះនរា
*ឧទាហរណ៍ល្អនៃការបង្កើតចក្ខុវិស័យតំបន់អភិវឌ្ឍន៍*

ដោយមានការគាំទ្រពី SMMR និង Build4-People, Impact Hub Phnom Penh (IHPP) បានចាប់ផ្ដើមដាក់ដំណើរការនៃទីតាំងបង្ហាញបណ្ដោះអាសន្ននៅកោះនរា ដើម្បីចូលរួមជាមួយសហគមន៍ និងប្រមូលយោបល់អំពីការផ្លាស់-ប្ដូរតំបន់នេះ ឱ្យក្លាយទីតាំងដ៏រស់រវើកមួយ។ សំណួរណែនាំសំខាន់របស់គម្រោងគឺ៖

» តើតម្រូវការ និងចំណង់ចំណូលចិត្តរបស់សាធារណជនអំពីរបៀបផ្លាស់ប្ដូរកោះនរាឱ្យក្លាយទៅជាគោលដៅរស់រវើក នោះមានអ្វីខ្លះ?

ក្នុងរយៈពេល ៨ថ្ងៃ (២៨ កុម្ភៈ ដល់ ១០ មិនា ២០២៤) IHPP បានស្ទង់មតិពី ប្រជាពលរដ្ឋពេញវ័យចំនួន ១០៤១នាក់ តាមរយៈសកម្មភាពអន្តរកម្មនៅតាមបណ្ដោយទន្លេ។ លទ្ធផលបានបង្ហាញអាទិភាពពីសាធារណជនចំពោះការរស់នៅក្នុងទីក្រុង ដែលផ្ដល់យោបល់ល្អៗ សម្រាប់ការអភិវឌ្ឍផ្អែកលើតម្រូវការនៅកោះនរា និងកន្លែងផ្សេងៗទៀត។

*លទ្ធផលចក្ខុវិស័យពីទីតាំងបង្ហាញបណ្ដោះអាសន្ន ដែលរៀបចំនៅកោះនរា*

- **អាទិភាពខ្ពស់៖**
  - » តំបន់បៃតង និងរុក្ខជាតិសាធារណៈ
  - » ការគ្រប់គ្រងសំណល់មានប្រសិទ្ធភាព
- **អាទិភាពមធ្យម៖**
  - » តំបន់សាធារណៈសហគមន៍
  - » សមាហរណកម្ម និងភាពងាយស្រួលក្នុងការចូលដំណើរការ
  - » សុវត្ថិភាព និងរបៀបរៀបរយសាធារណៈ
- **អាទិភាពមធ្យម-ទាប៖**
  - » ការដឹកជញ្ជូន និងភាពងាយស្រួលក្នុងការប្រើប្រាស់
  - » សោភ័ណភាព និងគុណភាពប្រើប្រាស់
  - » សកម្មភាពកម្សាន្ត និងសង្គម

ការបង្កើតចក្ខុវិស័យតាមបែបគុណភាព ជួយ-បំពេញការប្រមូលទិន្នន័យតាមបរិមាណនៅក្នុងសហគមន៏។ ទោះបីមិនមានសម្រង់សារពើភ័ណ្ឌផ្លូវការនៅកោះនរាក៏ដោយ ការយល់ឃើញទាំងនេះអាចផ្ដល់ព័ត៌មានសំខាន់សម្រាប់ការធ្វើផែនការសហគមន៏នាពេលអនាគត។

*គោលបំណងអាទិភាព ដែលទទួលបានពីទីតាំងបង្ហាញបណ្ដោះអាសន្ន ដែលរៀបចំនៅកោះនរា*

1. **ធានាឱ្យមានការប្រើប្រាស់ងាយស្រួលទៅរកការចល័តដោយមិនប្រើម៉ាស៊ីន**
   ផ្ដល់អាទិភាពដល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការដើរ និងជិះកង់ ដើម្បីបង្កើតបរិយាកាសទីក្រុងប្រកបដោយចីរភាព។
2. **លើកកម្ពស់ភាពរស់រវើកក្នុងសហគមន៏**
   បង្កើតតំបន់សកម្ម ដែលលើកទឹកចិត្តទំនាក់ទំនងសង្គម និងការរីកចម្រើនអាជីវកម្មក្នុងតំបន់។
3. **លើកកម្ពស់អារម្មណ៍ជាសហគមន៍**
   រចនាតំបន់តាមបែបសមាហរណកម្ម ដែលអាចឆ្លើយតបតាមតម្រូវការសង្គមមានភាពចម្រុះ។

# IV ការរៀបចំផែនការ




**រូបភាពទី ២២៖** គំនូរផែនការឌីជីថល។
ប្រភព៖ TUD WA ។



**រូបភាពទី ២៣៖** U_CODE ដែលកំពុងប្រើប្រាស់រៀបចំប្លង់បរិស្ថានសាកលវិទ្យាល័យ Dresden។
ប្រភព៖ TUD WA ។



**រូបភាពទី ២៤៖** U_CODE កំពុងប្រើប្រាស់រៀបចំ-សួនវិស្សមកាលនៅជិតសហគមន៍ PCMC នៃប្រទេសឥណ្ឌា។ សហការជាមួយ PULSE (កម្មវិធី India - Smart Cities Fellowship)។
ប្រភព៖ TUD WA ។

## ឧបករណ៍រៀបចំផែនការឌីជីថល
*UCODE*

### *ទិដ្ឋភាពទូទៅ*

U_CODE ជាវិធីសាស្ត្រ និងឧបករណ៍ឌីជីថលមួយ ដែលត្រូវបានរចនាឡើង ដើម្បីអនុញ្ញាតឱ្យមានការចូលរួមយ៉ាងទូលំទូលាយក្នុងការធ្វើផែនការទីក្រុង និងស្ថាបត្យកម្ម។ វាគាំទ្រការបញ្ចូលទិន្នន័យមានភាពធំទូលាយ បញ្ជាក់ឱ្យដឹងថា-តម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានរួមបញ្ចូលមានចរន្តទិន្នន័យបន្តពីការគិតគូររហូតដល់ការអនុវត្ត និងផ្ដល់អំណាចឲ្យមនុស្សរាប់ពាន់នាក់រួមគ្នារចនាទីក្រុង ដែលជាអនាគតរបស់ពួកគេ។ ដើម្បីកាត់បន្ថយឧបសគ្គក្នុងការចូលរួម ប្រព័ន្ធនេះអនុញ្ញាតឱ្យចូលប្រើប្រាស់បានគ្រប់ពេលវេលា និងលើកកម្ពស់ការចូលរួមរួមសកម្មរបស់ភាគីពាក់ព័ន្ធចម្រុះ។

U_CODE ជាវេទិកាចូលរួមបែប 3D ដ៏ច្នៃប្រឌិតសម្រាប់ការធ្វើផែនការទីក្រុង និងការធ្វើផែនការដឹកជញ្ជូន ដែលអនុញ្ញាតឱ្យអ្នកធ្វើផែនការអាចពង្រីកការចូលរួម ពីសាធារណជនយ៉ាងទូលំ-ទូលាយ និងងាយស្រួល។ ប្រព័ន្ធនេះនឹងកំណត់តម្រូវការសំខាន់ៗ សម្រាប់ការអភិវឌ្ឍថ្មីៗ ប្រា-ស្រ័យទាក់ទងគំនិត ការរៀបចំផែនការ និងការសម្រេចចិត្តឱ្យបានច្បាស់លាស់ ហើយប្រមូលមតិយោបល់ជាក់ស្ដែងពីសាធារណជន។

UCODE បានអភិវឌ្ឍនៅរយៈពេលឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៩ គឺជាផ្នែកមួយនៃគម្រោងអឺរ៉ុបហិរញ្ញប្បទានដោយស្ថាប័ន Horizon ២០២០ ដែលដឹកនាំដោយ មន្ទីរពិសោធន៍ WISSEN-SARCHITEKTUR ក្នុងសាកលវិទ្យាល័យបច្ចេកវិទ្យា Dresden។ ដៃគូគម្រោងរួមមាន TU Delft សហព័ន្ធឧស្សាហកម្ម Silicon Saxony ក្រុមហ៊ុន IT Oracle និងស្ថាបត្យករ gmp Architekten von Gerkan, Marg und Partner។ ក្នុងក្របខ័ណ្ឌការសហការនេះ ទាំងវិធីសាស្ត្រ និងឧបករណ៍ឌីជីថលត្រូវបានអភិវឌ្ឍជាបឋម ធ្វើតេស្តសាកល្បង និងបានអនុវត្ត។

### *លក្ខណៈពិសេសសំខាន់ៗ*

U_CODE ផ្ដល់ជូននូវកម្មវិធីចូលរួមតាមគេហបណ្ដាញ ដែលជំរុញឲ្យមានការទទួលស្គាល់លើគម្រោងធ្វើផែនការទីក្រុង និងគាំទ្រការរៀបចំ-ផែនការដោយមានការឯកភាពក្នុងដំណើរការធ្វើផែនការទាំងមូល។ សម្រាប់ការរចនា និងការធ្វើផែនការទីក្រុងទាំងនេះ វាបានតភ្ជាប់ប្រជា-ពលរដ្ឋ អ្នកជំនាញ និងរដ្ឋបាលសាធារណៈក្នុងបរិយាកាសរួមរចនាដោយប្រើ 3D ឌីជីថលដើម្បីអនុញ្ញាតឱ្យទទួលបានផល ដែលមានភាពច្បាស់លាស់ និងផ្ដោតលើលទ្ធផលត្រឹមត្រូវ ៖ Urban Co-Design ។

ដោយប្រើប្រាស់ឧបករណ៍ឌីជីថល ប្រជាពលរដ្ឋរាប់ពាន់នាក់ អាចរួមចំណែកបញ្ជូនព័ត៌មាន-សំណើសុំ និងគំនិតផ្ទាល់ខ្លួនរបស់ពួកគេបាន។ ទិន្នន័យទាំងនេះត្រូវបាន U_CODE វិភាគ និងរៀបចំឲ្យមានរចនាសម្ព័ន្ធ ដើម្បីអាចប្រើប្រាស់ដោយអ្នករៀបចំផែនការ និងអាជ្ញាធរពាក់ព័ន្ធ។

ដំណោះស្រាយ ដែលបានអភិវឌ្ឍ ត្រូវបានធ្វើតេស្តសាកល្បង និងអភិវឌ្ឍបន្ថែមក្នុងគម្រោងសាកល្បងជាច្រើនទូទាំងពិភពលោក ( រួមមានប្រទេសអាល្លឺម៉ង់ កេនយ៉ា ជប៉ុន ឥណ្ឌា)។




**រូបភាពទី ២៥៖** កញ្ចប់ឧបករណ៍ U_CODE កំពុងប្រើប្រាស់។
ប្រភព៖ WA_TUD ។




**រូបភាពទី ២៦៖** ទីក្រុង Nakuru នៃប្រទេសកេនយ៉ា។ សហការជាមួយ FES (Friedrich Ebert Stiftung) ក្នុងគម្រោង Just City។
ប្រភព៖ TUD WA ។







សិក្ខាសាលារចនារួមក្នុងស្រុកនៅទីក្រុង Fritz-Foester-Platz ។




| Alle Objekte | Gebäude | Natur | Stadtmobiliar | Nutzungen | Gebäudevolumen | Verhältnis Volumen Gebäude / Natur |
|---|---|---|---|---|---|---|
| 629 | 354 | 79 | 129 | 8 | 6,66 | 3.11215 |




កូដQR ទៅកាន់ WISSENSARCHITEKTUR មន្ទីរពិសោធន៍ស្ថាបត្យកម្មចំណេះដឹង
https://tu-dresden.de/bu/architektur-landschaft/wa

**រូបភាពទី ២៧៖** ការវិភាគលទ្ធផលនៃការចូលរួម Dresden Fritz Försterplatz សហការជាមួយនាយកដ្ឋានរៀបចំផែនការទីក្រុង Dresden ។
ប្រភព៖ TUD WA ។

# V ការវាយតម្លៃ និងការស្រាវជ្រាវ

## វិទ្យាសាស្ត្រប្រជាពលរដ្ឋ

*កម្មវិធី B4P សម្រាប់វិទ្យាសាស្ត្រប្រជាពលរដ្ឋ*




**រូបភាពទី ២៨៖** សកម្មភាពនៃកម្មវិធី B4P Citizen Science App។
ប្រភព៖ Build4People ។

### *ការណែនាំ*

វិទ្យាសាស្ត្រប្រជាពលរដ្ឋ ផ្តល់អត្ថប្រយោជន៍ជាច្រើន សម្រាប់ការធ្វើផែនការទីក្រុងប្រកបដោយចីរភាព ជាពិសេសក្នុងការគៀងគរការចូលរួមរបស់ប្រជាពលរដ្ឋ។ តាមរយៈការចូលរួមរបស់មនុស្សជាច្រើន គេអាចប្រមូលទិន្នន័យពហុបរិមាណអំពីបរិស្ថានទីក្រុងបានប្រសើរ។ ទិន្នន័យទាំងនេះបង្កើតជាមូលដ្ឋានទិន្នន័យលម្អិត ដែលរួមបញ្ចូលទស្សនៈរបស់អ្នករស់នៅ ក្នុងនាមជាអ្នកជំនាញប្រចាំថ្ងៃ ចំពោះស្ថានភាពទីកន្លែងរស់នៅរបស់ពួកគេ។ វិធីសាស្ត្រនេះ មិនត្រឹមតែបង្កើនបរិមាណទិន្នន័យទេ ប៉ុន្តែថែមទាំងធ្វើឲ្យគុណភាពរបស់ទិន្នន័យល្អប្រសើរឡើង ដោយរួមបញ្ចូលចំណេះដឹងមូលដ្ឋាន ដែលជាវិធីសាស្ត្រប្រមូលទិន្នន័យធម្មតាបានមើលរំលង។
ក្រៅពីការប្រមូលទិន្នន័យ វិទ្យាសាស្ត្រប្រជាពលរដ្ឋក៏បង្កើតលំហពិតប្រាកដសម្រាប់ការចូលរួម ដើម្បីឲ្យប្រជាពលរដ្ឋអាចចូលរួមក្នុងការកំណត់ទិសដៅទីក្រុងរបស់ពួកគេដោយផ្ទាល់។ ដំណើរការចូលរួមនេះជួយបង្កើនការយល់ដឹងអំពីបញ្ហាទីក្រុង ពង្រឹងអារម្មណ៍នៃភាពជាម្ចាស់ និងការភ្ជាប់មនុស្សទៅនឹងបរិយាកាសរស់នៅរបស់ពួកគេ។ តាមរយៈការចូលរួមរបស់អ្នករស់នៅក្នុងការតាមដាន និងវាយតម្លៃលំហទីក្រុង ពួកគេក្លាយជាភ្នាក់ងារសំខាន់មួយ ក្នុងការគាំទ្រការផ្លាស់ប្តូរទីក្រុងសមាហរណកម្ម និងចីរភាពកាន់តែប្រសើរ។
បច្ចេកវិទ្យាទំនើប ដូចជាកម្មវិធី (apps) ដែលងាយស្រួលប្រើ និងវេទិកាអនឡាញ បានធ្វើឲ្យដំណើរការចូលរួមនេះកាន់តែងាយស្រួល តាមរយៈការសម្របសម្រួលការផ្តល់ទិន្នន័យ ការទំនាក់ទំនង និងតម្លាភាពក្នុងព័ត៌មាន។ ឧបករណ៍ទាំងនេះបានបង្កើត "រង្វិលតប" រវាងប្រជាពលរដ្ឋ និងអ្នករៀបចំផែនការទីក្រុង ដែលធ្វើឲ្យការសម្រេចចិត្តកាន់តែច្បាស់លាស់ និងកសាងភាពទុកចិត្តលើរដ្ឋបាលមូលដ្ឋាន។
អត្ថប្រយោជន៍សំខាន់មួយនៃវិទ្យាសាស្ត្រប្រជាពលរដ្ឋ គឺសមត្ថភាពរបស់វាក្នុងការលើកកម្ពស់សមាហរណកម្មសង្គម។ ការចូលរួមយ៉ាងសកម្មរបស់ក្រុមប្រជាជនផ្សេងៗជាច្រើន ជាពិសេសក្រុមសម្លេងតិច ឬមិនមានតំណាងគ្រប់គ្រាន់ ធ្វើឲ្យប្រាកដថា ការអភិវឌ្ឍទីក្រុងឆ្លុះបញ្ចាំងតាមតម្រូវការរបស់អ្នករស់នៅគ្រប់រូប។ កម្មវិធីនេះពង្រីកការចូលរួម មិនត្រឹមតែផ្នែកបរិមាណទេ ប៉ុន្តែថែមទាំងផ្នែកគុណភាពផងដែរ។ តាមរយៈការរួមបញ្ចូលវិធីសាស្ត្រវិទ្យាសាស្ត្រជាមួយការចូលរួមយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ វិទ្យាសាស្ត្រប្រជាពលរដ្ឋ អាចអនុញ្ញាតឱ្យមានការធ្វើផែនការទីក្រុងដែលមានការចូលរួម ការសម្របខ្លួន និងសមភាព ដែលរួមចំណែកបង្កើនចីរភាព និងគុណភាពរស់នៅ រយៈពេលវែងសម្រាប់ទីក្រុង។

### *កម្មវិធី B4P សម្រាប់វិទ្យាសាស្ត្រប្រជាពលរដ្ឋ*

វិទ្យាសាស្ត្រប្រជាពលរដ្ឋ ផ្តល់អត្ថប្រយោជន៍ជាច្រើន សម្រាប់ការធ្វើផែនការទីក្រុងប្រកបដោយចីរភាព។ តាមរយៈការចូលរួមរបស់មនុស្សជាច្រើន គេអាចប្រមូលទិន្នន័យបែបបរិមាណជាច្រើនអំពីបរិស្ថានទីក្រុង។ ទិន្នន័យទាំងនេះអាចត្រូវបានប្រើប្រាស់ ដើម្បីបង្កើតមូលដ្ឋានទិន្នន័យលម្អិត ដែលរួមបញ្ចូលទស្សនៈរបស់ប្រជាពលរដ្ឋ ក្នុងនាមជាអ្នកជំនាញប្រចាំថ្ងៃលើបរិយាកាសរស់នៅរបស់ពួកគេ។

**រូបភាពទី ២៩៖** វិធីសាស្ត្ររបស់ Build4People ក្នុងការភ្ជាប់វិទ្យាសាស្ត្រប្រជាពលរដ្ឋជាមួយទីតាំងជាក់ស្តែង។
ប្រភព៖ រៀបចំដោយខ្លួនឯង ។




វិទ្យាសាស្ត្រប្រជាពលរដ្ឋ តាមរយៈកម្មវិធីទូរស័ព្ទចល័តមានសមត្ថភាពលំអិតច្រើន ដែលអនុញ្ញាតឱ្យក្រុមប្រជាជនជាច្រើន រួមទាំងក្រុមដែលតែងត្រូវបានគេមើលរំលង ឬមិនមានតំណាងគ្រប់គ្រាន់អាចធ្វើវិភាគទានពីតម្រូវការពិសេស និងទស្សនៈរបស់ពួកគេក្នុងដំណើរការធ្វើផែនការ។

កម្មវិធី Build4People Citizen Science (B4P CS App) អាចជំរុញការរចនាទីក្រុងប្រកបដោយសមាហរណកម្មជាងមុន។ អ្នករៀបចំផែនការទទួលបានព័ត៌មានមានតម្លៃតាមរយៈ B4P CS App ដែលអាចបំពេញបន្ថែមដល់ការវិភាគរបស់អ្នកជំនាញ ស្របពេលជំនួយដល់ការពង្រឹងអត្តសញ្ញាណរបស់ប្រជាពលរដ្ឋរាជធានីភ្នំពេញ។

កម្មវិធី B4P CS មានតួនាទីជាឧបករណ៍ចូលរួមមានភាពបត់បែន ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋទីក្រុងប្រើទូរស័ព្ទរបស់ពួកគេ ដើម្បីវាយស្ថានភាពសាងសង់ និងបរិយាកាសរស់នៅដោយផ្អែកលើកត្តាគុណភាពជីវិតជាច្រើន ព្រមទាំងអនុវត្តតាមលទ្ធផល តាមផែនទីឌីជីថលដោយប្រើផែនទីអនឡាញ។

តាមរយៈការធ្វើបែបនេះ កម្មវិធីបានផ្តល់ឱកាសប្រមូលការវាយតម្លៃទៅតាមគោលដៅលើតំបន់ទីក្រុងផ្សេងៗ ហើយបញ្ចូលចំណេះដឹងទាំងនេះក្នុងដំណើរការធ្វើផែនការទីក្រុង។ ជាឧបករណ៍សម្រាប់ការចូលរួម ដោយផ្អែកលើទិន្នន័យជាគោល App នេះនឹងអាចអភិវឌ្ឍបន្ថែមទៅជាកម្មវិធី PPCH-CS-App ដែលជាវេទិកាទំនាក់ទំនងអន្តរកម្ម ដែលភ្ជាប់រដ្ឋបាលរាជធានី និងពលរដ្ឋរបស់រាជធានីភ្នំពេញ។

កម្មវិធីនេះត្រូវបានរចនាឡើង ដើម្បីលើកកម្ពស់ការអភិវឌ្ឍទីក្រុងប្រកបដោយសមាហរណកម្ម ដោយអនុញ្ញាតឱ្យក្រុមជាក់លាក់ដូចជា ជនពិការ កុមារ មនុស្សចាស់ ឬស្ត្រីអាចវាយតម្លៃជាប្រព័ន្ធលើតំបន់ទីក្រុង ។ វិធីសាស្ត្រនេះ ធ្វើឲ្យកំណត់បាននូវទីតាំង ដែលអាចពង្រឹងសមាហរណកម្មតាមរយៈការសាងសង់ និងវិធានការរចនាទីក្រុង ព្រមទាំងអភិវឌ្ឍផែនការសកម្មភាព ដើម្បីលើកកម្ពស់ការធ្វើផែនការទីក្រុង មានភាពរួមបញ្ចូលកាន់តែខ្លាំង។





**រូបភាពទី ៣០៖** ការធ្វើតេស្តសាកល្បងជាការពិតនៃកម្មវិធី B4P CS App ជាមួយនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅក្នុងវិទ្យាស្ថាន RUPP កាលពី ខែធ្នូ ឆ្នាំ២០២៤។
ប្រភព៖ Build4People


សេចក្ដីណែនាំ ០២.៦









**រូបភាពទី ៣១៖** រួមគ្នារចនាទីក្រុងក្នុងគោលបំណងរបស់ “Kiezlabor” គឺដើម្បីអនុញ្ញាតឱ្យមនុស្សអាចចូលរួមបង្កើតតំបន់រស់នៅរបស់ពួកគេបានច្រើនតាមដែលអាចធ្វើទៅបាន។
ប្រភព៖ ស៊ីធីឡាប Berlin ។

## ការសហការរៀបចំបរិវត្តកម្មទីក្រុង

*ឧទាហរណ៍ពីយុទ្ធសាស្ត្ររបស់ ស៊ីធីឡាប BERLIN*

### *ការណែនាំ*

ស៊ីធីឡាប Berlin ដែលដំណើរការដោយ Technologiestiftung Berlin និងមានមូលនិធិឧបត្ថម្ភពី Berlin Senate Chancellery គឺជាការច្នៃប្រឌិតសាធារណៈមួយ ដែលប្រមូលផ្តុំរដ្ឋបាលសាធារណៈ សង្គមស៊ីវិល និងបច្ចេកវិទ្យាឌីជីថលមករួមគ្នា ដើម្បីសហការបង្កើត “ទីក្រុងអនាគត”។ ស៊ីធីឡាប Berlin ផ្តល់ជូននូវផ្លូវដើរ ឧបករណ៍ និងវិធីសាស្ត្រការងារ ដែលបានសាកល្បងរួច ដើម្បីជួយជំរុញ “បរិវត្តកម្មពីរផ្លូវ (Twin Transformation)” ប្រកបដោយជោគជ័យទាំងចីរភាព និងប្រព័ន្ធឌីជីថល ដែលមានគោលបំណងច្បាស់លាស់។

### *បច្ចេកវិទ្យាស៊ីវិលរបស់ទីក្រុងប៉ែរឡាំងក្នុងការអនុវត្ត*

ស៊ីធីឡាប មិនមែនជាគ្រឹះស្ថានសិក្សាវិចារណកថាតែមួយទេ វាជាវេទិកាសម្រាប់ការអនុវត្តផ្ទាល់។ គម្រោងរបស់ស៊ីធីឡាប បង្ហាញយ៉ាងច្បាស់ថាឧបករណ៍ឌីជីថល និងការចូលរួមរបស់សហគមន៍ផ្តល់ផលវិជ្ជមាន និងកំណត់ទិសដៅការអភិវឌ្ឍទីក្រុងបានដោយផ្ទាល់៖

- **Kiezlabor៖** មន្ទីរពិសោធន៍ចល័តមួយ ដែលធ្វើចុះជាប់តាមសង្កាត់ ផ្តល់កន្លែងឱ្យប្រជាពលរដ្ឋចូលរួមបានដោយផ្ទាល់ និងជំរុញការពិភាក្សាក្នុងសហគមន៍។
- **Climate Dashboard Xhain៖** ផ្ទាំងព័ត៌មានបណ្តោះអាសន្នមួយរបស់កម្មវិធី Xhain ដែលបង្ហាញទិន្នន័យអាកាសធាតុ និងបរិស្ថាន ដើម្បីផ្តល់ជាព័ត៌មានជួយជំរុញ ផ្នែកគោលនយោបាយ និងតវិយាបទសាធារណៈឱ្យមានការយល់ដឹងកាន់តែច្បាស់។
- **Parla៖** ជាវេទិកាចូលរួមមួយ ដែលតាមដានមតិបាតសាធារណៈ នៅតាមខណ្ឌនានាក្នុងទីក្រុង ដើម្បីបង្កើនតម្លាភាព និងការទុកចិត្តរបស់ប្រជាពលរដ្ឋ។
- **Energy Checkpoint៖** ជាមជ្ឈមណ្ឌលធនធានមួយ សម្រាប់តាមដានទិន្នន័យថាមពលរបស់សង្កាត់ និងលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ថាមពល។

ឧបករណ៏នេះបង្ហាញថា នវានុវត្តឌីជីថលអាចបម្រើបរិវត្តកម្មទីក្រុងតាមរយៈការផ្តល់ព័តមាន និងផ្តល់ឪកាសដល់ពលរដ្ឋ។

### *ការផ្តល់អំណាចដល់ប្រព័ន្ធអេកូស៊ីស្ទឹមទីក្រុងឆ្លាតវៃ*

ស៊ីធីឡាប មានតួនាទីសំខាន់នៅក្នុងការអនុវត្តយុទ្ធសាស្ត្រ ទីក្រុងឆ្លាតវៃរបស់ទីក្រុងប៉ែរឡាំង “Gemeinsam Digital: Berlin” (ឌីជីថលរួមគ្នា៖ ប៉ែរឡាំង) ដែលផ្តោតលើតម្លៃសាធារណៈ ផលប៉ះពាល់ និងកិច្ចសហការរៀបចំ។ មន្ទីរពិសោធន៍នេះ ធ្វើឲ្យកើតមានការសហការរវាងរដ្ឋាភិបាល សហគមន៍បច្ចេកវិទ្យា និងប្រជាពលរដ្ឋ ដែលជាប្រព័ន្ធអេកូស៊ីឡូបែបសមាហរណកម្មមួយ ដែលមជ្ឈមណ្ឌលទីក្រុងឆ្លាតវៃនៃរាជធានីភ្នំពេញអាចដើរតាមគន្លងនេះបាន។






**រូបភាពទី ៣២៖** សន្ទស្សន៍ឥទ្ធិពលកំដៅ បង្ហាញពីតំបន់មួយចំនួននៅទីក្រុងបែឡាំង ដែលរងឥទ្ធិពលកម្តៅខ្លាំងដែលគេហៅថា “hotspots”។ សន្ទស្សន៍នេះរួមបញ្ចូលកត្តាចម្រុះៗ ដូចជា សីតុណ្ហភាពផ្ទៃដី កម្រិតភាពងាយរងផលប៉ះពាល់បរិស្ថាន (បរិមាណដើមឈើ កម្រិតគម្របដី) កម្រិតភាពងាយរងផលប៉ះពាល់ដល់មនុស្ស (ដង់ស៊ីតេមនុស្សចំនួនមនុស្សអាយុលើស ៦៥ ឆ្នាំ និងក្រោម ១០ ឆ្នាំ សន្ទស្សន៍ស្ថានភាពសង្គម និងចំនួននិយោជិត)។
ប្រភព៖ ស៊ីធីឡាប Berlin ។

- *ទាបខ្លាំង*
- *ទាប*
- *មធ្យម*
- *ខ្ពស់*
- *ខ្ពស់ខ្លាំង*

### *ផ្លូវជាយុទ្ធសាស្ត្រសម្រាប់ការសហការណ៍*

បទពិសោធន៍របស់ស៊ីធីឡាប អាចគាំទ្រដោយផ្ទាល់ដល់បរិវត្តកម្មពីរផ្លូវ នៅក្នុងបរិបទទីក្រុងប្រទេសកម្ពុជា៖

- **ការបង្កើតមជ្ឈមណ្ឌលច្នៃប្រឌិតមូលដ្ឋាន៖** មណ្ឌលពិសោធន៍មួយ ក្នុងរាជធានីភ្នំពេញបានទទួលឥទ្ធិពលពីគំរូ ស៊ីធីឡាប ដែលត្រូវបានសហការបង្កើតឡើងជាមួយដៃគូដូចជា សាកលវិទ្យាល័យ Impact Hub ឬ Factory Phnom Penh។ មជ្ឈមណ្ឌលនេះអាចធ្វើជាទីតាំងសម្រាប់រៀបចំសិក្ខាសាលារចនារួម ការធ្វើតេស្តសាកល្បងឧបករណ៍ឌីជីថល និងការចូលរួមរបស់ភាគីពាក់ព័ន្ធ។
- **ការអនុវត្តឧបករណ៍ទិន្នន័យសម្រាប់តម្លាភាព៖** ឧបករណ៍ដូចជា ផ្ទាំងទិន្នន័យអាកាសធាតុ ឬ Parla អាចត្រូវបានបន្សាំ សម្រាប់រាជធានីភ្នំពេញ ដោយប្រើទិន្នន័យមូលដ្ឋានពីកម្មវិធី B4P Citizen Science App ដើម្បីជំរុញវប្បធម៌នៃការផ្តល់មតិយោបល់ត្រឡប់ និងការបើកចំហផ្សព្វផ្សាយជាសាធារណៈ។
- **ការផ្តល់យោបល់លើអភិបាលកិច្ចទីក្រុងឆ្លាវៃ៖** បទពិសោធន៍របស់ស៊ីធីឡាប នៅក្នុងយុទ្ធសាស្ត្រឌីជីថលរបស់ទីក្រុង ប៉ែរឡាំង អាចផ្តល់អត្ថប្រយោជន៍ដល់ការខិតខំរបស់រាជធានីភ្នំពេញ នៅក្នុងការសម្របសម្រួលគោលដៅទីក្រុងបៃតង និងទីក្រុងឆ្លាតវៃ តាមរយៈសវនាការនយោបាយពហុភាគី។
- **ការហ្វឹកហ្វឺន “បណ្តុះគ្រូបង្គោល” សម្រាប់ការចូលរួម៖** វិធីសាស្ត្រ និងចំណេះដឹងរបស់ស៊ីធីឡាប អាចពង្រឹងកម្មវិធីបណ្តុះបណ្តាល ដោយផ្តល់ដល់ដៃគូក្នុងស្រុកនូវឧបករណ៍ និងជំនាញ ដើម្បីដឹកនាំដំណើរការធ្វើផែនការប្រកបដោយសមាហរណកម្ម។

### *សេចក្តីសន្និដ្ឋាន៖ សម្ព័ន្ធភាពឆ្លងតំបន់សម្រាប់បរិវត្តកម្មទីក្រុង*

ស៊ីធីឡាបបែឡាំងមិនត្រឹមតែផ្តល់ជាឧបករណ៍បច្ចេកទេសទេ ប៉ុន្តែថែមទាំងផ្តល់ទស្សនវិស័យមួយផងដែរ ដែលបង្ហាញថា បរិវត្តកម្មឌីជីថលអាចមានការចូលរួមរបស់សាធារណៈ មិនសូវមានឧបសគ្គ និងផ្តោតលើមនុស្សជាមូលដ្ឋាន។

ជាដៃគូអភិវឌ្ឍនៅក្នុងដំណាក់កាលអនុវត្តន៍នៃគម្រោង B4P ស៊ីធីឡាបអាចជួយឲ្យរាជធានីភ្នំពេញអភិវឌ្ឍន៍ មិនត្រឹមតែរបៀបធ្វើផែនការ ប៉ុន្តែថែមទាំងរបៀបស្តាប់ របៀបបញ្ជោប និងរបៀបច្នៃប្រឌិតផងដែរ។
យើងអាចរួមគ្នាបង្កើតសម្ព័ន្ធភាពការសិក្សាឆ្លងតំបន់មួយ ដែលទីក្រុងប៉ែរឡាំង និងរាជធានីភ្នំពេញរួមគ្នារចនាអនាគតទីក្រុងល្អប្រសើរជាងមុន ដោយផ្អែកលើតម្លៃរួម និងសកម្មភាពរួមរបស់សហគមន៍។



**រូបភាពទី ៣៣៖** វេទិកាអនឡាញ "Fairgnügen" ជាកម្មវិធីងាយស្រួលប្រើ មានមុខងារស្វែងរក ចម្រាញ់ និងការភ្ជាប់ទីតាំងភូមិសាស្ត្រ ដើម្បីធ្វើឱ្យសេវាផ្សេងៗអាចប្រើប្រាស់បានស្រួល តាមលក្ខខណ្ឌជីវភាព និងចំណាប់អារម្មណ៍របស់អ្នកប្រើប្រាស់។
ប្រភព៖ ស៊ីធីឡាប Berlin ។

កូដ QR ទៅកាន់ស៊ីធីឡាប Berlin citylab-berlin.org/en/



សេចក្តីណែនាំ ០២.៦

# VI កិច្ចការទៅអនាគត

## នឹងត្រូវពិភាក្សាបន្ថែមជាមួយភាគីពាក់ព័ន្ធ ក្នុងដំណាក់កាលអនុវត្តកម្មវិធី B4P ឆ្នាំ ២០២៥-២០២៧

ដើម្បីគាំទ្ររាជធានីភ្នំពេញក្នុងដំណើរបរិវត្តកម្មរបស់ខ្លួនកាន់តែមានចីរភាព និងគុណភាពជីវិតទីក្រុងកាន់តែប្រសើរ រាជធានីភ្នំពេញមានឱកាសមានតម្លៃសម្រាប់ការអភិវឌ្ឍន៍ និងបង្កើតដំណើរការចូលរួមកាន់តែសកម្មក្នុងការធ្វើផែនការ។

ការអភិវឌ្ឍ និងអនុវត្តន៍ការធ្វើផែនការចូលរួម គឺជាដំណើរការ ដែលមានការកែប្រែបន្តបន្ទាប់ និងទាមទារការចូលរួមសកម្ម ពីភាគីពាក់ព័ន្ធច្រើន (ឧ. ក្រុមហ៊ុនអភិវឌ្ឍឯកជន អាជ្ញាធររដ្ឋ និងប្រជាពលរដ្ឋក្នុងទីក្រុង) ព្រមទាំងការកសាងទំនុកចិត្តរវាងគ្នា។

មិនមែនដំណើរការចូលរួមគ្រប់ប្រភេទសមស្របសម្រាប់គោលបំណង ទីតាំង ឬក្រុមគោលដៅគ្រប់ប្រភេទទេ។ ដូច្នេះ ឧបករណ៍ចូលរួមត្រូវ-អភិវឌ្ឍឱ្យសមស្របនឹងបរិបទពាក់ព័ន្ធ ដោយជាក់លាក់។ ការចូលរួមមិនបានចាប់ផ្តើមត្រឹមតែការប្រើប្រាស់ឧបករណ៍ ធ្វើផែនការចូលរួមទេ ប៉ុន្តែចាប់ផ្តើមពីការអភិវឌ្ឍឧបករណ៍ទាំងនោះឱ្យសមស្របជាមុនសិន។

ឱកាសដ៏សំខាន់មួយគឺការប្រើប្រាស់ឧបករណ៍ធ្វើផែនការឌីជីថល និងវិធីសាស្ត្រចូលរួមតាមប្រព័ន្ធឌីជីថលដូចជា ឧបករណ៍ដែលបានរួម-បញ្ចូលក្នុងគម្រោងតាមរយៈស៊ីធីឡា បបែឡាំង (ឧ. Climate Dashboard Xhain) និងមន្ទីរពិសោធន៍ Knowledge Architecture (ឧ. U_CODE) នៃសាកលវិទ្យាល័យបច្ចេកទេស-ដ្រេសដឹន។
ឧបករណ៍ចូលរួមតាមប្រព័ន្ធឌីជីថលអាចផ្តល់នូវភាពបត់បែនខ្ពស់ប្រកបដោយតម្លាភាព ការកាត់បន្ថយឧបសគ្គ និងការចូលប្រើបានទូលំ-ទូលាយជាងមុន។ ទោះបីជាយ៉ាងណា ការប្រើ-ប្រាស់ឧបករណ៍ឌីជីថល មិនអាចធានាបាន-ដោយស្វ័យប្រវត្តិថា នឹងនាំឱ្យមានការចូលរួមជោគជ័យនោះទេ។ ដូច្នេះ កិច្ចការនេះត្រូវតែចាត់ទុកជាផ្នែកមួយនៃគំនិត សម្រាប់ការចូលរួម-ទូលំទូលាយ។

ដូច្នេះ គម្រោងណែនាំឱ្យធ្វើតេស្តសាកល្បងលើវិធីសាស្ត្រទាំងអស់ដែលបានបង្ហាញនៅទីនេះ (ទាំងវិធីសាស្ត្រធម្មតា ឌីជីថល និងឧបករណ៍ផ្សេងៗ) ក្នុងបរិបទខុសៗគ្នា ដោយរួមបញ្ចូលភាគីពាក់ព័ន្ធនានា ដើម្បីអាចបម្លែង បន្សាំ ឬកែតម្រូវឱ្យសមស្រប តាមស្ថានភាពពិតប្រាកដ និងធានាឱ្យមានការវាយតម្លៃបន្តបន្ទាប់អំឡុងដំណើរការ។
នៅក្នុងបរិបទបរិវត្តកម្ម និងចំណេះដឹងចម្រុះ-វិស័យនេះ ការវាយតម្លៃក្នុងដំណើរការមិនគួរត្រូវបានកំណត់ត្រឹមតែ ការពិនិត្យលើលក្ខណៈការវាយតម្លៃជោគជ័យបែបអរូបីនោះទេ។ ផ្ទុយពីនេះ លក្ខណៈវាយតម្លៃទាំងនេះ គួរត្រូវបានអភិវឌ្ឍរួមគ្នាជាមួយនឹងតំណាងរដ្ឋបាលក្រុង និងភាគីពាក់ព័ន្ធពាក់ព័ន្ធ។
ដំណើរការវាយតម្លៃបន្តបន្ទាប់គួរត្រូវបានយល់ដឹងថា ជាយន្តការគាំទ្រជាបន្តបន្ទាប់ មិនមែនជាឧបករណ៍ត្រឹមតែវាយតម្លៃតែប៉ុណ្ណោះទេ។ យន្តការនេះ ជួយឱ្យរដ្ឋបាលក្រុងអាចបង្កើននូវប្រសិទ្ធភាព ដំណើរការចូលរួមឱ្យកាន់តែប្រសើរនៅក្នុងទិសដៅឆ្ពោះទៅពេលអនាគត។
ដើម្បីលើកកម្ពស់ នៃការទទួលយកដំណើរការចូលរួម និងលើកទឹកចិត្តឱ្យសាធារណជន និងភាគីពាក់ព័ន្ធចូលរួមគម្រោង Build4People សូមណែនាំឱ្យប្រើឧបករណ៍ផ្សព្វផ្សាយសង្គម។ ការអភិវឌ្ឍយុទ្ធនាការទាំងនេះគួរត្រូវរួមបញ្ចូលការវិភាគភាគីពាក់ព័ន្ធ ដើម្បីយល់ឱ្យបានច្បាស់អំពីតម្រូវការ និងទស្សនៈរបស់ក្រុមគោលដៅព្រមទាំងការរលើកទឹកចិត្ត ដែលបញ្ចូល-ការប្រើប្រាស់បណ្តាញផ្សព្វផ្សាយផ្សេងៗគ្នា និងរចនាសម្ព័ន្ធលើកទឹកចិត្តសមស្រប។ វិធីសាស្ត្របែបនេះអាចបង្កើនការគាំទ្រដល់ការចូលរួមនៅក្នុងរយៈពេលមធ្យម ហើយដោយប្រយោល និងអាចពង្រឹងទំនុកចិត្តចំពោះរដ្ឋបាលមូលដ្ឋានផងដែរ។

ការកែលម្អគុណភាពជីវិត នៅក្នុងរាជធានីភ្នំពេញ គឺជាកិច្ចការសង្គមមួយផងដែរ។ ការចូលរួមរក្សាតួនាទីសំខាន់ក្នុងដំណើរការបរិវត្តកម្មនេះ ជាពិសេសក្នុងការសម្រេច-បាននូវរចនាសម្ព័ន្ធគ្រប់គ្រងអភិបាលកិច្ចដែលប្រសើរឡើង។

# VII ឯកសារយោង


Arnstein, S. R. (1975). A working model for public participation. Public Administration Review 35, 70-73.

Bell, S. & Morse, S. (2012). Resilient participation. Saving the human project? Milton Park: Routledge.

Conrad, E.; Cassar, L.F.; Christie, M.; Fazev, I.(2011). Hearing but not listening? A participatory assessment of public participation in planning. Environ. Plan. C Gov. Policy 29, 761–782.

DAC-SG, Disability Action Council General Secretariat (2018): Technical Standards on Physical Accessibility Infrastructure for Persons with Disabilities. https://access2cambodia.org/wp-content/uploads/2024/10/4.DAC-HI_Technical%20Standards%20on%20Physical%20Accessibility-Eng-Compressed.pdf

Dellenbaugh-Losse, Mary (2024): Gendergerechte Stadtentwicklung – Wie wir eine Stadt für alle bauen. Springer Gabler Wiesbaden. https://doi.org/10.1007/978-3-658-45290-2.

Deuß, A., Theis, A., Serey, S., Vanna, O. & Blöbaum, A. (2025). Predictors of the Intention to Adopt Residential Photovoltaics in Cambodia – A Psychological Perspective. Asian Journal of Social Psychology, 28. https://doi.org/10.1111/ajsp.12674

Few, R., Brown, K. & Tompkins, E. L. (2007). Public participation and climate change adaptation: avoiding the illusion of inclusion. Climate Policy 7, 46-59.

Griskevicius, V., Cialdini, R.B. & Goldstein, N.J. (2008). Applying (and Resisting) Peer Influence. MIT Sloan Management Review.


សេចក្តីណែនាំ ០២.៦

Horelli, L. (2002): A methodology of participatory planning. In: R. Bechtel, u. A. Churchman (Eds.): Handbook of environmental psychology. Wiley. New York, NY: 607–628.

Jayaweera, R., Nop, S., Karagianni, C., Waibel, M. and Schwede, D. (2022). Sustainable building arenas: Constructing a governance framework for a sustainability transition in Cambodia’s urban built environment. IOP Conf. Ser.: Earth Environ. Sci. 1078 012084.

Jayaweera, R., Rohracher, H., Becker, A., Waibel, M. (2023). Houses of cards and concrete: (In)stability configurations and seeds of destabilisation of Phnom Penh’s building regime. Geoforum, 141 (2023) 103744. ISSN 0016-7185, https://doi.org/10.1016/j.geoforum.2023.103744.

Jayaweera, R., Waibel, M. (2024). The Build4People’s Sustainable Building Arena – an example for an urban transition lab in the Global South. Activity Report. SURE Solutions Publication, Volume 1, 24-31.

Lee, N. R., & Kotler, P. (2015). Social marketing: Changing behaviors for good. Sage Publications.

Municipal Department of Vienna, Section Urban Development and Planning (2013): Manual for Gender Mainstreaming in Urban Planning and Urban Development. https://afakneswiah.org/wp-content/uploads/2020/10/b008358.pdf.

Nielsen, K.S., Cologna, V., Bauer, J.M., Berger, S., Brick, C., Dietz, T., Hahnel, U. J. J., Henn, L., Lange, F., Stern, P.C., & Wolske, K.S. (2024). Realizing the full potential of behavioural science for climate change mitigation. Nature Climate Change, 14(4), 322–330. https://doi.org/10.1038/s41558-024-01951-1.

Steg, L. & Nordlund, A. (2012): Models to explain environmental behaviour. In L. Steg, et al. (Eds.): Environmental psychology – An introduction (pp. 185-195). Chichester, West Sussex.

Tyler, T. R. (2000). Social Justice: Outcome and procedure. International Journal of Psychology, 35, 117-125.

Van Zomeren, M. (2015). Psychological processes in social action. In: M. Mikulincer & P. R. Shaver (Eds.) / J.F. Dovidio & J.A. Simpson (Eds.): APA Handbook of Personality and Social Psychology (Vol. 2). APA Press. Washington, DC: 507-533.

WomenWatch (2009): Gender Equality and Sustainable Urbanisation. Factsheet. https://www.un.org/womenwatch/feature/urban/downloads/WomenWatch_Gender_Equality_and_Sustainable_Urbanisation-fact_sheet.pdf.

World Bank Group (2020): Handbook for Gender-Inclusive Urban Planning and Design. https://openknowledge.worldbank.org/bitstream/handle/10986/33197/145305.pdf.

## អ្នកនិពន្ធ

*Anke Blöbaum, Department of Environmental Psychology, Otto-von-Guericke University Magdeburg*
*Michael Waibel, Department of Geography, University of Hildesheim*
*Anja Jannack, Laboratory of Knowledge Architecture at TU Dresden*
*Yannick Müller, CityLAB Berlin, Germany*
*Sovanarith Sieng, UN-Habitat Bangkok Programme Office, formerly SMMR project*
*Christina Karagianni, Department of Sustainable Building Technology, Technical University of Applied Sciences Lübeck*
*Andreas Deuß, Department of Environmental Psychology, Otto-von-Guericke University Magdeburg*

## អ្នកត្រួតពិនិត្យ

*Rolf Messerschmidt, Eble Messerschmidt Partner, Tübingen, Germany*
*Sokunlanita May, Chair of die Association Women in Architecture and Engineering in Cambodia (W.A.E.)*
*Tep Makathy, Cambodian Institute for Urban Studies (CIUS)*

## សម្រួលជាខេមរភាសា

*លោកស្រី គល់ សុជាតា*
*InDesignដោយ៖ ហៃ ប៊ុនហុង និងហេង វឌ្ឍន:*

## គោលគំនិតនិងការរៀបចំក្រាហ្វិក

EBLE MESSERSCHMIDT PARTNER
Architekten und Stadtplaner PartGmbB

## ថ្លែងអំណរគុណ

*សេចក្តីណែនាំនេះត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌគម្រោង Build4People ក្រោមការណែនាំរបស់កញ្ចប់ការងារ B4P “ការផ្លាស់ប្តូរឥរិយាបទ” និង “បរិវត្តកម្មទៅកាន់ទីក្រុងប្រកបដោយចីរភាព” ។*

## បោះពុម្ពផ្សាយ និងលេខទំនាក់ទំនង

Dr. Anke Blöbaum
Prof. Dr. Ellen Matthies
Department of Environmental Psychology
Universitätsplatz 2
39106 Magdeburg, Germany
anke.bloebaum@ovgu.de
ellen.matthies@ovgu.de

# BUILD4PEOPLE
## លក្ខណៈវិនិច្ឆ័យ និងទិដ្ឋភាព ទូទៅនៃសេចក្តីណែនាំលើការ រចនាទីក្រុងបែបសមាហរណកម្ម




ស្កេនខ្ញុំ! ...
.... ដើម្បីទាញយក TOOLBOX ឯកសារផ្សេងទៀត ដែលរៀបចំឡើងដោយ B4P!
















